លំនៅឋានមនុស្សជាតិកម្ពុជា
Habitat for Humanity®
Cambodia






# កសាងភាពធន់
# កសាងអនាគតដ៏ភ្លឺស្វាង

ការលើកកម្ពស់ការសាងសង់លំនៅឋានដែលធន់នឹងអាកាសធាតុ និងការលើកកម្ពស់ សហគមន៍ប្រកបដោយបរិយាបន្ន និងភាពធន់

របាយការណ៍ប្រចាំឆ្នាំសារពើពន្ធ ២០២៥
០១ ខែកក្កដា ឆ្នាំ ២០២៤ – ៣០ ខែមិថុនា ឆ្នាំ ២០២៥

# មាតិកា

**១. សារចំណាប់អារម្មណ៍ពីនាយកប្រចាំប្រទេស ........ ៤**

**២.អំពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ........ ៥**

២.១. ចក្ខុវិស័យ បេសកកម្ម និងគោលការណ៍ ........ ៥

២.២. អំពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ........ ៦

២.៣. ស្ថានភាពទូទៅនៃប្រទេសកម្ពុជា ........ ៧

**៣. ទិសដៅយុទ្ធសាស្ត្ររបស់យើង ........ ៩**

៣.១. ការណែនាំអំពីក្របខណ្ឌយុទ្ធសាស្ត្រថ្មីរបស់យើង ឆ្នាំសារពើពន្ធ ២០២៦–២០២៨ ........ ៩

៣.២. វិសាលភាពកម្មវិធី ........ ១០

៣.៣. ការអនុវត្តស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ........ ១២

**៤. សមិទ្ធផលសំខាន់ៗ ........ ១៤**

៤.១. សមិទ្ធផលសំខាន់ៗក្នុងរយៈពេល ២២ ឆ្នាំ នៅប្រទេសកម្ពុជា ........ ១៤

៤.២. សមិទ្ធផលសំខាន់ៗក្នុងឆ្នាំសារពើពន្ធ ២០២៥៖ ចំនួនគ្រួសារ និងអ្នកទទួលផលពីគម្រោង ........ ១៥

៤.៣. អន្តរាគមន៍ស្របនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ........ ១៦

**៥. សមិទ្ធផលសំខាន់ៗតាមកម្មវិធី ........ ១៧**

៥.១. កម្មវិធីអាទិភាពទី ១៖ កម្មវិធីសាងសង់លំនៅឋានប្រកបដោយភាពធន់ ........ ១៧

៥.២. កម្មវិធីអាទិភាពទី ២៖ កម្មវិធីពង្រឹងអភិបាលកិច្ច និងប្រព័ន្ធគោលនយោបាយលំនៅឋាន ........ ២១

៥.៣. កម្មវិធីអាទិភាពទី ៣៖ កម្មវិធីជម្រុញវឌ្ឍនភាពទីផ្សារលំនៅឋាន ........ ២៨

៥.៤. ការងារស្ម័គ្រចិត្តសម្រាប់ការអភិវឌ្ឍសហគមន៍ ........ ២៩

- សកម្មភាពស្ម័គ្រចិត្តសម្រាប់យុវជន និងអ្នកស្ម័គ្រចិត្តក្នុងស្រុក ........ ៣០
- ការចូលរួមក្នុងកម្មវិធីស្ម័គ្រចិត្តអន្តជាតិ ........ ៣១

**៦. ទិដ្ឋភាពទូទៅផ្នែកហិរញ្ញវត្ថុ ........ ៣២**

៦.១. ចំណូល និងចំណាយ ........ ៣២

**៧. ដៃគូ និងអ្នកផ្តល់ជំនួយ ........ ៣៣**

**៨. ការចូលរួមរបស់អ្នកជាមួយយើងខ្ញុំ ........ ៣៧**


Habitat for Humanity® Cambodia
Habitat for Humanity® Cambodia
Habitat for Humanity® Cambodia
Habitat for Humanity® Cambodia
Habitat for Humanity® Cambodia

# ១ សារចំណាប់អារម្មណ៍ពីនាយកប្រចាំប្រទេស



ខ្ញុំមានសេចក្តីសោមនស្សក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជាសម្រាប់ឆ្នាំសារពើពន្ធ ២០២៥។ ឆ្នាំនេះគឺជាពេលវេលាដែលការិយាល័យប្រចាំប្រទេសរបស់ពួកយើងបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តសកម្មភាពស្របតាមយុទ្ធសាស្ត្រប្រចាំតំបន់និងសកលលោក ៥០/៥០ និងដំណើការអភិវឌ្ឍន៍ស្ថាប័នប្រកបដោយចីរភាពតាមរយៈដំណើរការផ្លាស់ប្រែ។

ការប្តេជ្ញាចិត្តនេះបាននាំមកនូវទាំងឱកាស និងឧបសគ្គប្រឈម ប៉ុន្តែពួកយើងតែងតែពុះពារដើម្បីលើកកម្ពស់ការសាងសង់លំនៅឋានឱ្យបានកាន់តែច្រើន ប្រសើរឡើង និងមានភាពធន់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងការធ្វើឱ្យប្រសើរឡើងលើការងារអភិបាលកិច្ចលំនៅឋាន និងលើកកម្ពស់ការអនុវត្តគោលនយោបាល ដែលស្របទៅតាមបេសកកម្មរបស់អង្គការលំនៅឋានមនុស្សជាតិ៖ មនុស្សគ្រប់រូបសក្តិសមនឹងមានជម្រកដ៏មានសុវត្ថិភាព និងសមរម្យមួយសម្រាប់ហៅថា “ផ្ទះ”។

ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ ពួកយើងបានមើលឃើញពីសាមគ្គីភាព និងប្រសិទ្ធិភាពកិច្ចសហប្រតិបត្តិការរវាងក្រុមការងារ និងដៃគូរបស់យើង ដែលជំរុញដោយជំនឿ និងការប្តេជ្ញារួម ក្នុងការឆ្លើយតបទៅនឹងតម្រូវការលំនៅឋាននៅកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការបរិច្ចាគទាំងធនធាន សំភារៈ និងបច្ចេកទេសទាំងអស់ ដែលបង្កើតបាននូវការផ្លាស់ប្តូរដ៏មានអត្ថន័យ និងយូរអង្វែងសម្រាប់ជីវិតរបស់គ្រួសារ និងសហគមន៍ជាច្រើន។

ខណៈពេលដែលឆ្នាំសារពើពន្ធនេះបានបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីឆ្លុះបញ្ចាំង អំពីសមិទ្ធផលដែលពួកយើងបានសម្រេចរួមគ្នា និងអ្វីដែលកំពុងរង់ចាំពួកយើងនាពេលអនាគត។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងាររបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជាទាំងអស់ចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការពង្រឹងសមត្ថភាពស្ថាប័នរបស់ពួកយើងដើម្បីធ្វើឱ្យមានផលជះវិជ្ជមានទៅលើរាប់ពាន់គ្រួសារនៅក្នុងឆ្នាំសារពើពន្ធ២០២៥។

នៅឆ្នាំខាងមុខ ពួកយើងនឹងបន្តផ្តោតលើការសាងសង់លំនៅឋានដែលមានភាពធន់ ការពង្រឹងគោលនយោបាយ និងអភិបាលកិច្ចលំនៅឋាន ព្រមទាំងបង្កើតផលជះវិជ្ជមានដល់ទីផ្សារលំនៅឋានសង្គម និងមានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប និងងាយរងគ្រោះបំផុត រួមទាំងអ្នកដែលតាំងទីលំនៅមិនរៀបរយផងដែរ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូរដ្ឋាភិបាល អង្គការដៃគូមិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រៅស្រុក ដៃគូសហគមន៍ និងអ្នកគាំទ្រទាំងអស់ សម្រាប់ការចូលរួមដ៏មានតម្លៃតាមរយៈការផ្តល់ជាថវិកា ការស្ម័គ្រចិត្ត ឬការគាំទ្រផ្នែកតស៊ូមតិ។ ការចូលរួមរបស់អ្នកទាំងអស់គ្នាបង្កើតបានជាមូលដ្ឋានគ្រឹះនៃបេសកកម្មរបស់ពួកយើង ក្នុងការកសាងក្តីសង្ឃឹមយូរអង្វែងសម្រាប់គ្រួសារ និងសហគមន៍។

**លោក ផល វ៉ាន់ឌី**
នាយកប្រចាំប្រទេស

# ២ អំពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា

## ២.១. ចក្ខុវិស័យ បេសកកម្ម និងគោលការណ៍

### ចក្ខុវិស័យ

ពិភពលោកមួយដែលមនុស្សគ្រប់គ្នាមានកន្លែងសមរម្យសម្រាប់រស់នៅ។

### បេសកកម្ម

ពិភពលោកមួយដែលមនុស្សគ្រប់គ្នាមានកន្លែងសមរម្យសម្រាប់រស់នៅ។

### គោលការណ៍

- បង្ហាញសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ
- ផ្តោតលើទីជម្រក
- តស៊ូមតិសម្រាប់លំនៅឋានសមរម្យ
- លើកកម្ពស់សេចក្តីថ្លៃថ្នូរ និងក្តីសង្ឃឹម
- គាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការផ្លាស់ប្តូរជាវិជ្ជមាន



# ២.២ អំពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា

ដោយទទួលបានការជំរុញពីចក្ខុវិស័យដែលមនុស្សគ្រប់គ្នាត្រូវការកន្លែងរស់នៅសមរម្យ អង្គការលំនៅឋានមនុស្សជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ ដែលជាកិច្ចខិតខំប្រឹងប្រែងកំរិតសហគមន៍ និងចាប់តាំងពីពេលនោះមក ពួកយើងបានរីកចម្រើនក្លាយជាអង្គការមិនរកប្រាក់ចំណេញសកលលោកឈានមុខគេ និងកំពុងធ្វើប្រតិបត្តិការនៅជាង ៦០ ប្រទេសជុំវិញពិភពលោក។

នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការលំនៅឋានមនុស្សជាតិបានជួយគាំទ្រដល់ប្រជាជនរាប់លាននាក់តាមរយៈការសាងសង់ និងកែលម្អលំនៅឋានដែលពួកគេអាចរស់នៅបានហៅថា “ផ្ទះ” ចាប់តាំងពីឆ្នាំ ១៩៨៣ មកម្ល៉េះ។ តាមរយៈជំនួយផ្នែកហិរញ្ញវត្ថុ ការស្ម័គ្រចិត្ត ឬសំឡេងគាំទ្រមតិដើម្បីលើកកម្ពស់លំនៅឋានដែលមានតម្លៃសមរម្យ អ្នកគ្រប់គ្នាសុទ្ធតែអាចជួយគ្រួសារឱ្យសម្រេចបាននូវភាពរឹងមាំ ស្ថិរភាព និងឯករាជ្យភាពលើខ្លួនឯង ដែលពួកគេត្រូវការសម្រាប់កសាងជីវិតរបស់ខ្លួនឱ្យកាន់តែមានភាពប្រសើរឡើង។

**១៨៨,០០០ គ្រួសារ**

ចាប់តាំងពីឆ្នាំ២០០៣មក អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានជួយគាំទ្រប្រជាពលរដ្ឋជាង ១៨៨,០០០ គ្រួសារ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ តាមរយៈបទអន្តរាគមន៍ផ្នែកលំនៅឋាន (រួមមាន៖ ការសាងសង់លំនៅឋានថ្មី និងការកែលម្អលំនៅឋាន លំនៅឋានសង្គមកិច្ច ការផ្តល់សុវត្ថិភាពដីធ្លី ការកែលម្អនៅទីតាំងផ្ទាល់ និងការផ្តល់លទ្ធភាពទទួលបានហិរញ្ញប្បទានលំនៅឋាន) ការស្តារឡើងវិញ និងការពង្រឹងភាពធន់នឹងគ្រោះមហន្តរាយផ្នែកលំនៅឋាន (HDRR) ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (CCA) ការគ្រប់គ្រងសំណល់រឹង បរិក្ខារទឹកស្អាត និងអនាម័យ (WASH) កម្មវិធីអភិវឌ្ឍន៍សហគមន៍ និងភាពជាដៃគូជាមួយក្រុមចម្រុះនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រៅស្រុក ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដៃគូសាជីវកម្ម អាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិ។





# ២.៣ ស្ថានភាពទូទៅនៃប្រទេសកម្ពុជា

ចំនួនប្រជាជនសរុប
**១៧.៦ លាននាក់**
(ឆ្នាំ ២០២៤)

ចំនួនប្រជាជននៅទីក្រុង
**២៥.៤%**
(ឆ្នាំ ២០២៣)

ចំនួនប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រ
**១៦.៦%**
(ឆ្នាំ ២០២៣)

ចំនួនប្រជាជននៅទីក្រុងដែលរស់នៅក្នុងតំបន់ក្រីក្រ៖ ប្រមាណ
**៤០%**
(ឆ្នាំ ២០២០)

ចំនួនគ្រួសារសរុបក្នុងប្រទេសកម្ពុជា
**៣.៦ លានគ្រួសារ**
(ឆ្នាំ ២០១៩-២០២០)

គ្រួសារដែលមានស្ត្រីជាមេគ្រួសារ
**២១.៥%**
(ឆ្នាំ ២០២២)

ចំនួនប្រជាជនមានសេវាទឹកស្អាតប្រើប្រាស់
**២៩%** (ឆ្នាំ ២០២៣)

ចំនួនប្រជាជនមានកន្លែងលាងដៃត្រឹមត្រូវ
**៨៣.៤%** (ឆ្នាំ ២០២២)

ចំនួនប្រជាជនមានសេវាអនាម័យប្រើប្រាស់
**៣៧%** (ឆ្នាំ ២០២២)

ចំនួនគ្រួសារប្រើប្រាស់ប្រភពទឹកមិនទាន់កែលម្អ
**២០.៣%** (ឆ្នាំ ២០១៩-២០២០)

កម្រូវការលំនៅឋានដែលបានប៉ាន់ស្មាននៅឆ្នាំ ២០៣០
**កម្ពុជាត្រូវការលំនៅឋានថ្មីចំនួន ១,១ លានខ្នង**

**គ្រោះធម្មជាតិ ដូចជារន្ទះ ខ្យល់កន្ត្រាក់ និងទឹកជំនន់ ក្នុងឆ្នាំ ២០២៤៖**
(គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ)

ប្រជាជនជាង
**១០០ នាក់**
បានបាត់បង់ជីវិត និង ៨៦ នាក់ទៀតបានរងរបួស

**២២ ខេត្ត**
ចំនួនគ្រោះទឹកជំនន់បង្កផលប៉ះពាល់ដល់ខេត្តនិងបណ្តាលឱ្យគ្រួសារជាង ៥៩,២៥០ គ្រួសារត្រូវរងគ្រោះ

**២៨.៧៧៥ ហិកតា**
ដីស្រែបានរងការខូចខាត

*** Sources:**

- Asian Development Bank
- National Housing Policy 2014
- National Committee for Disaster Management (NCDM) Report 2024
- Multidimensional Poverty Index 2023, UNDP
- World Bank 2022
- World Bank 2023
- World Bank 2024



# ៣ ទិសដៅយុទ្ធសាស្ត្ររបស់យើង

## ៣.១. ការណែនាំអំពីក្របខណ្ឌយុទ្ធសាស្ត្រថ្មីរបស់យើង FY២០២៦-FY២០២៨




គោលនយោបាយជាតិស្តីពីលំនៅឋានឆ្នាំ ២០១៤ បានបង្ហាញថា ប្រទេសកម្ពុជាត្រូវការលំនៅឋានបន្ថែមចំនួន ១,១ លានខ្នង នៅត្រឹមឆ្នាំ ២០៣០ [1]។

នៅឆ្នាំ ២០២៥ ប្រជាជននៅតំបន់ទីប្រជុំជនចំនួន ៤២,៣% (ស្មើនឹង ១,៧៨៨,០២៨ នាក់) កំពុងរស់នៅក្នុងតំបន់សំណង់មិនរៀបរយ ឬលំនៅឋានដែលមានលក្ខខណ្ឌមិនសមរម្យ ដែលងាយរងគ្រោះដោយសារគ្រោះមហន្តរាយអាកាសធាតុ[2][3]។

ចំនួនប្រជាជនសរុបនៅតំបន់ទីប្រជុំជនមាន ៤,២៣០,០៣៥ នាក់ (ស្មើនឹង ២៥% នៃប្រជាជនសរុប ១៦,៨៤៣,៣៣៣ នាក់) ហើយត្រូវបានរំពឹងថានឹងកើនឡើងដល់ ៣០,៦% នៅឆ្នាំ ២០៣០ និង ៤១,១% នៅឆ្នាំ ២០៥០[4]។

គិតត្រឹមឆ្នាំ ២០២៥ គ្រួសារប្រមាណ ៣១% នៅកម្ពុជា (ស្មើនឹង ១,២១៦,៩០៩ គ្រួសារ នៃចំនួនគ្រួសារសរុប ៣,៩០៦,៦៦៥ គ្រួសារ) គឺជាគ្រួសារក្រីក្រ (ស្ថិតក្នុងបន្ទាត់ភាពក្រីក្រ) ឬគ្រួសារងាយរងហានិភ័យ (ស្ថិតនៅលើបន្ទាត់ភាពក្រីក្របន្តិច)។ ក្នុងនោះមានគ្រួសារក្រីក្រចំនួន ៧១៥,២៤៤ និងគ្រួសារងាយរងហានិភ័យចំនួន ៥០១,៦៦៥[5]។ គ្រួសារក្រីក្រ ឬងាយរងហានិភ័យនៅកម្ពុជាជិត ៤៧% មានស្ត្រីជាមេគ្រួសារ ដែលឆ្លុះបញ្ចាំងពីស្ថានភាពយេនឌ័រនៃភាពក្រីក្រ បង្កឡើងដោយកង្វះធនធាន ប្រព័ន្ធគាំពារសង្គមនៅមានកម្រិត និងបន្ទុកនៃការថែទាំគ្រួសារដោយមិនទទួលបានកម្រៃ។

ប្រជាជនកម្ពុជា ៨៧% មានលទ្ធភាពប្រើប្រាស់ទឹកស្អាតកម្រិតមូលដ្ឋាន ខណៈមានតែ ២១% ប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាតដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព។ ប្រជាជនប្រមាណ ៩២% មានលទ្ធភាពប្រើប្រាស់អនាម័យកម្រិតមូលដ្ឋាន ប៉ុន្តែមានតែ ៥១% ប៉ុណ្ណោះដែលមានលទ្ធភាពប្រើប្រាស់អនាម័យដែលត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព[6]។

កម្ពុជាគឺជាប្រទេសដែលងាយរងគ្រោះខ្ពស់ដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ដែលប៉ះពាល់ដល់ស្ថិរភាពសង្គម-សេដ្ឋកិច្ច និងសន្តិសុខស្បៀង។ ប្រសិនបើគ្មានវិធានការបន្សាំទេនោះ ការប្រែប្រួលអាកាសធាតុអាចបណ្តាលឱ្យខាតបង់រហូតដល់ ៩% នៃផលិតផលក្នុងស្រុកសរុប (GDP) នៅត្រឹមឆ្នាំ ២០៥០ និងបង្កើនអត្រាភាពក្រីក្រ ៦% នៅត្រឹមឆ្នាំ ២០៤០[7]។ ស្ត្រីនៅកម្ពុជាមានសន្ទស្សន៍ភាពធន់ទាបជាងបុរស គឺ ០,៥៦ ធៀបនឹង ០,៥៩ (យោងតាមអង្គការ ActionAid Cambodia ឆ្នាំ ២០២១)។

**ប្រភព៖** ១) ការស្នើសុំគោលនយោបាយកម្ពុជា (២) កម្មវិធីរបស់អង្គការសហប្រជាជាតិសម្រាប់ការតាំងទីលំនៅមនុស្ស (UN-Habitat)៖ របាយការណ៍ប្រទេសកម្ពុជា ឆ្នាំ ២០២៤ (៣) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៖ មូលដ្ឋានទិន្នន័យសូចនករគន្លឹះ (៤) ក្រសួងផែនការ៖ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) (៥) របាយការណ៍ Knight Fran៖ តម្រូវការកើនឡើងនៃលំនៅឋានតម្លៃសមរម្យ និងលំនៅឋានដែលមានយីហោល្បីនៅកម្ពុជា និងតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ឆ្នាំ ២០២៥ - ចុះផ្សាយដោយ Cambodia Investment Review (៦) សារព័ត៌មាន ខ្មែរថាមស៍ (៧) ធនាគារពិភពលោក ឆ្នាំ ២០២៣៖ ការចាត់វិធានការលើការប្រែប្រួលអាកាសធាតុ គឺជាគន្លឹះសម្រាប់កម្ពុជាក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់ខ្លួន)

11 SUSTAINABLE CITIES AND COMMUNITIES | 5 GENDER EQUALITY | 6 CLEAN WATER AND SANITATION | 13 CLIMATE ACTION

**ចក្ខុវិស័យ**

**ពិភពលោកមួយដែលមនុស្សគ្រប់គ្នាមានកន្លែងសមរម្យសម្រាប់រស់នៅ**

**គោលដៅ**

**អង្គការលំនៅឋានមនុស្សជាតិ កម្ពុជា មានបំណងបង្កើតផលជះវិជ្ជមានដល់ជីវិតប្រជាជនចំនួន ១,៨៤៩,២៣៦ នាក់ នៅកម្ពុជាត្រឹមឆ្នាំ ២០២៨។**

| សាងសង់លំនៅឋានឱ្យបានច្រើនជាងមុន និងល្អប្រសើរជាងមុន | ការផ្លាស់ប្តូរប្រព័ន្ធលំនៅឋាន | បំផុសសកម្មភាពដើម្បីលំនៅឋាន |
|---|---|---|
| លើកកម្ពស់លក្ខខណ្ឌលំនៅឋានជូនប្រជាជនជាង៣៩,២០០ នាក់ (ស្ត្រី ១៩,៦០០ នាក់)តាមរយៈ: ការសាងសង់ថ្មី ការជួសជុល ការកែលម្អ ការស្តារឡើងវិញ និងការសាងសង់បន្ថែមជាដំណាក់កាល។ | ប្រជាជន **១៥៩,៣១០ នាក់ (ស្ត្រី ៧៩,៦០០ នាក់)** មានលទ្ធភាពទទួលបានលំនៅឋានតម្លៃសមរម្យ តាមរយៈការអភិវឌ្ឍទីផ្សារ។ ពង្រឹងជំហររបស់អង្គការលំនៅឋាន ដើម្បីរួមចំណែកដល់ការផ្លាស់ប្តូរគោលនយោបាយ ដែលជំរុញឱ្យមានលទ្ធភាពទទួលបានលំនៅឋានប្រកបដោយគុណភាព និងតម្លៃសមរម្យ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាជន **១,៦៤៧,៦០៦ នាក់ (ស្ត្រី ៨២៣,៨០០ នាក់)**។ | កៀរគរមនុស្សយ៉ាងតិច **៣,១២០ នាក់ (ស្ត្រី ១,៥០០ នាក់)** និងធ្វើឱ្យមានការចូលរួមឱ្យកាន់តែស៊ីជម្រៅជុំវិញបញ្ហាលំនៅឋាន។ |

**អាទិភាពកម្មវិធី**

**កម្មវិធីសាងសង់លំនៅឋានប្រកបដោយភាពធន់៖** ដើម្បីកសាងសហគមន៍ជនបទ និងទីប្រជុំជនប្រកបដោយភាពធន់ និងបរិយាបន្ន តាមរយៈលំនៅឋានដែលមានសុវត្ថិភាព និងពេញលេញ ដោយរួមបញ្ចូលការងារអាកាសធាតុចម្រុះ ការពង្រឹងភាពធន់នឹងគ្រោះមហន្តរាយផ្នែកលំនៅឋាន និងការទទួលបានសេវាមូលដ្ឋានដោយសមធម៌។

**កម្មវិធីពង្រឹងអភិបាលកិច្ច និងប្រព័ន្ធលំនៅឋាន៖** ដើម្បីរួមចំណែកដល់ការអភិវឌ្ឍ ការកែលម្អ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយលំនៅឋាន ប្រព័ន្ធ និងការផ្តល់សេវា ឆ្ពោះទៅសម្រេចបានលំនៅឋានដែលមានសុវត្ថិភាព ភាពពេញលេញ និងតម្លៃសមរម្យ។

**កម្មវិធីជម្រុញវឌ្ឍនភាពទីផ្សារលំនៅឋាន៖** ដើម្បីបង្កើនលទ្ធភាពចូលទៅកាន់ទីផ្សារលំនៅឋានតម្លៃសមរម្យ តាមរយៈការអភិវឌ្ឍសមត្ថភាព និងកសាងភាពជាដៃគូស្តីពីហិរញ្ញប្បទានលំនៅឋានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានចំណូលទាបនៅកម្ពុជា។

**កម្មវិធីអាទិភាពអន្តរវិស័យ៖** **ការបំផុសសកម្មភាពដើម្បីលំនៅឋាន៖ អ្នកស្ម័គ្រចិត្តដើម្បី/ក្នុងការអភិវឌ្ឍ ដែលកៀរគរអ្នកស្ម័គ្រចិត្ត និងការចូលរួមរបស់ស្ថាប័ន ដើម្បីកសាង និងជះឥទ្ធិពលលើបុព្វហេតុនៃបញ្ហាលំនៅឋាន។ **សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) **គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) **ភាពជាដៃគូ និងកិច្ចសន្ទនាប្រកបដោយលក្ខណៈស្ថាបនា **សមត្ថភាពស្ថាប័ន និងការអភិវឌ្ឍប្រកបដោយចីរភាព **ការពង្រឹងគំរូប្រតិបត្តិការ ប្រព័ន្ធ និងដំណើរការ **គុណភាពកម្មវិធី នវានុវត្តន៍ ការត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL) ** ការទំនាក់ទំនង និងភាពមើលឃើញនៃយីហោ **អភិបាលកិច្ច ការអនុលោមតាម សុវត្ថិភាព និងសន្តិសុខ ការគ្រប់គ្រងហានិភ័យ **ការកៀរគរធនធាន។

**ប្រជាជនគោលដៅ**

**អង្គការលំនៅឋានមនុស្សជាតិ ធ្វើការជាមួយប្រជាជនដែលមានលក្ខខណ្ឌលំនៅឋានមិនសមរម្យ ដោយសារការដាច់ចេញនៃប្រព័ន្ធ និងភាពងាយរងគ្រោះ**

| អ្នករស់នៅតំបន់សំណង់មិនរៀបរយ និង សំណង់បណ្តោះអាសន្ន | ស្ត្រី និងប្រជាជនងាយរងគ្រោះ* | អ្នកមានប្រាក់ចំណូលទាប** |
|---|---|---|

**និន្នាការសំខាន់ៗ**

**អង្គការលំនៅឋានមនុស្សជាតិ ឆ្លើយតបទៅនឹងសម្ពាធ និងការប៉ះទង្គិចនានា ដែលធ្វើឱ្យកង្វះខាតលំនៅឋាននៅតែបន្តមាន និងកើនឡើង**

| នគរូបនីយកម្ម | គោលនយោបាយ និងអភិបាលកិច្ច | ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ | ភាពក្រីក្រពហុវិមាត្រ |
|---|---|---|---|

# ៣.២. វិសាលភាពកម្មវិធី

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះនឹងអនុវត្តផ្តោតលើតំបន់កម្មវិធីអាទិភាពចំនួនពីរ ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។ តំបន់កម្មវិធីនៅប្រចាំរាជធានីភ្នំពេញនឹងគ្របដណ្តប់លើបណ្តុំខេត្តក្រុងក្បែរខាងរួមមាន៖ ភ្នំពេញ កណ្តាល និងកំពង់ឆ្នាំង។ ចំណែកឯតំបន់កម្មវិធីប្រចាំខេត្តសៀមរាបនឹងគ្របដណ្តប់លើបណ្តុំខេត្តក្រុងរួមមាន៖ សៀមរាប បាត់ដំបង និងបន្ទាយមានជ័យ។

ទោះជាយ៉ាងណាក៏ដោយ អង្គការលំនៅឋានមនុស្សជាតិកម្ពុជានៅតែបន្តពិចារណាលើតំបន់យុទ្ធសាស្ត្រផ្សេងៗទៀតផ្អែកលើតម្រូវការលំនៅឋាន និងឱកាសដែលផ្តល់ឱ្យដើម្បីបង្កើតផលវិជ្ជមានសម្រាប់លក្ខខណ្ឌរស់នៅ និងសេវាជាមូលដ្ឋាន ដើម្បីលើកកម្ពស់ភាពធន់នៃវិស័យលំនៅឋាននៅកម្ពុជា។




ខេត្តប្រតិបត្តិការនៅក្នុង FY25
ខេត្តសក្តានុពលក្នុងការពង្រីកបន្ថែម


Habitat for Humanity® Cambodia

# ៣.៣. ការអនុវត្តស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

តារាងខាងក្រោមបង្ហាញពីសមិទ្ធផលសំខាន់ៗ កើតចេញពីគំនិតផ្តួចផ្តើមរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា ក្នុងឆ្នាំសារពើពន្ធ ២០២៥ ដែលបង្ហាញពីផលជះវិជ្ជមានដែលយើងមានទៅលើគ្រួសារ និងសហគមន៍ស្របតាមគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព (SDGs)។ សមិទ្ធផលទាំងនេះ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់យើង ដែលផ្តោតលើពីការផ្តល់នូវលំនៅឋាន ប៉ុន្តែយើងថែមទាំងបានជំរុញឱ្យមានការផ្លាស់ប្តូរ និងលើកកម្ពស់ភាពធន់នៅក្នុងសហគមន៍ប្រកបដោយចីរភាព ទាំងនេះឆ្លុះបញ្ចាំងពីការរួមចំណែកដោយផ្ទាល់ ឬដោយប្រយោល ដើម្បីអាចឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។



## ការចូលរួមចំណែកដល់គោលដៅដោយផ្ទាល់




**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១១ - ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព៖** លំនៅឋានជំរុញវឌ្ឍនភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សាងសង់ និងកែលម្អផ្ទះ ផ្លូវថ្នល់ ប្រព័ន្ធលូ និងថាមពលដើរដោយពន្លឺព្រះអាទិត្យ បានពង្រឹងទាំងសហគមន៍នៅក្នុងទីក្រុង និងជនបទ។ យើងក៏បានចូលរួមកែលម្អតំបន់សំណង់បណ្តោះអាសន្ន និងសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានដំណោះស្រាយលំនៅឋានតម្លៃសមរម្យផងដែរ។




**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦-ទឹកស្អាត និងអនាម័យ៖** ការទទួលបានទឹក និងអនាម័យដែលមានសុវត្ថិភាព និង តម្លៃសមរម្យ គឺជាសិទ្ធិមនុស្ស ហើយក៏ជាសមាសធាតុសំខាន់មួយនៃលំនៅឋានដែលមានភាពពេញលេញ និងសុខភាពល្អ។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងក្រុម ប៉ាសា ដើម្បីសាងសង់ប៉មស្តុកទឹកនៅសាលារៀន និងកន្លែងលាងដៃ ដែលផ្សារភ្ជាប់គ្រួសារទៅនឹងតឹកស្អាត និងបង្គន់អនាម័យ




**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៣-សកម្មភាពបរិស្ថាន៖** លំនៅឋានប្រកបដោយចីរភាពជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សាងសង់ផ្ទះប្រកបដោយភាពធន់ ដែលផ្ទះទាំងអស់ត្រូវបានរចនាឡើងឱ្យត្រូវនឹងអាកាសធាតុត្រូពិចក្នុងប្រទេសកម្ពុជា កាត់បន្ថយហានិភ័យ និងពង្រឹងសមត្ថភាពសហគមន៍ទប់ទល់នឹងគ្រោះធម្មជាតិ។ យើងក៏ផ្តល់ការបណ្តុះបណ្តាលអ្នកភូមិនូវការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយដើម្បីឱ្យពួកគាត់បន្សាំខ្លួនទៅនឹងអាកាសធាតុ។

# ការចូលរួមចំណែកដល់គោលដៅដោយប្រយោល

1 NO POVERTY

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១-ពុំមានភាពក្រីក្រ៖** លំនៅឋានពេញលេញ កាត់បន្ថយនូវភាពងាយរងគ្រោះ ចំពោះវិបត្តិសេដ្ឋកិច្ច សង្គម សុខភាព និងបញ្ហាទាក់ទងនឹងអាកាសធាតុ។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សាងសង់លំនៅឋានដែលមានស្ថិរភាព និងសុវត្ថិភាព រួមទាំងជាដៃគូជាមួយភាគីពាក់ព័ន្ធក្នុងការស្វែងរកការគាំទ្រដើម្បីធ្វើឱ្យមាន លំនៅឋានតម្លៃសមរម្យ សិទ្ធិដីធ្លី និងការរស់រានមានជីវិតប្រកបដោយចីរភាព។

3 GOOD HEALTH AND WELL-BEING

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣-សុខភាព និងសុខុមាលភាពមាំមួន៖** លំនៅឋានប្រកបដោយស្ថិរភាព និងសុវត្ថិភាព គឺពិតជាមានសារៈសំខាន់ចំពោះសុខភាពផ្លូវកាយ និងផ្លូវចិត្ត។ នៅក្នុងឆ្នាំសារពើពន្ធ២០២៥ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានសាងសង់លំនៅឋានធន់នឹងអាកាសធាតុ បន្ទប់ទឹក ប៉មស្តុកទឹកនៅសាលារៀន និងកន្លែងលាងដៃ ខណៈពេលដែលផ្តល់ការបណ្តុះបណ្តាល និងឧបករណ៍បង្ការ ជំងឺកូវីដ-១៩ ដែលបានផ្តល់អត្ថប្រយោជន៍ដល់គ្រួសារ សិស្សានុសិស្ស និងសហគមន៍ទាំងមូល។

4 QUALITY EDUCATION

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំប្រកបដោយគុណភាព៖** ស្ថិរភាព និងលំនៅឋានប្រកបដោយ សុវត្ថិភាពបង្កើតឱកាសកាន់តែល្អប្រសើរដល់សិស្សានុសិស្សក្នុងការរៀនសូត្រ និងរីកចម្រើន។ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា គាំទ្រដល់ការអប់រំតាមរយៈកម្មវិធីបណ្តុះបណ្តាលអំពីជំនាញ និងការកសាងសមត្ថភាពក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងការសាងសង់ប្រកបដោយគុណភាព។ យើងក៏រៀបចំព្រឹត្តិការណ៍ចែករំលែកចំណេះដឹងទាក់ទងនឹងច្បាប់ស្តីពីលំនៅឋាន សុខភាព និងអាកាសធាតុ ពង្រឹងអំណាចដល់សហគមន៍តាមរយៈការផ្តល់ចំណេះដឹង និងជំនាញសំខាន់ៗ។

9 INDUSTRY, INNOVATION AND INFRASTRUCTURE

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៩-ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ៖** បច្ចេកវិទ្យាថ្មីផ្តល់នូវដំណោះស្រាយលំនៅឋាន តម្លៃសមរម្យ ប្រកបដោយភាពធន់ និងមិនប៉ះពាល់ដល់បរិស្ថាន។ តាមរយៈកម្មវិធីភាពធន់ក្នុង សហគមន៍របស់យើង យើងសហការជាមួយក្រុមប៉ាសា និងភាគីពាក់ព័ន្ធដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅលើទីតាំងលំនៅឋានសំណង់បណ្តោះអាសន្ន ដោយធ្វើឱ្យប្រសើរឡើងនូវផ្ទះ បង្គន់ ដំឡើងបង្គោលថាមពលដើរដោយពន្លឺព្រះអាទិត្យ និងដាក់ឱ្យប្រើប្រាស់បច្ចេកទេសកសិកម្មប្រកបដោយនវានុវត្តន៍សម្រាប់ការដាំដុះស្បៀងតាមផ្ទះ។



# ៤ សមិទ្ធផលសំខាន់ៗ

## ៤.១. សមិទ្ធផលសំខាន់ៗសម្រាប់រយៈពេល ២២ ឆ្នាំនៅប្រទេសកម្ពុជា

**២០០៣**

### ២០០២-២០០៣

- ចាប់ផ្តើមប្រតិបត្តិការនៅកម្ពុជា
- ចុះបញ្ជីជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គាំទ្រគ្រួសារដែលមានប្រាក់ចំណូលទាបចំនួន ៣៦គ្រួសារ តាមរយៈកម្មវិធីឥណទានតូចសម្រាប់លំនៅឋាន

**២០០៧**

### ២០០៤-២០០៧

- ចាប់ផ្តើមកម្មវិធីអ្នកស្ម័គ្រចិត្តពិភពលោក (អ្នកស្ម័គ្រចិត្តអន្តរជាតិ)
- ចាប់ផ្តើមកម្មវិធីទឹកស្អាត និងអនាម័យ

**២០០៩**

### ២០០៨-២០០៩

- រៀបចំកម្មវិធីសាងសង់ the Carter Work Project
- ចាប់ផ្តើមកម្មវិធី DR3
- ចាប់ផ្តើមកម្មវិធីសម្បទានដីសង្គម

**២០១២**

### ២០១០-២០១២

- អនុវត្តគម្រោងសម្បទានដីសង្គមនៅខេត្តបាត់ដំបង
- ចាប់ផ្តើមកម្មវិធីហិរញ្ញវត្ថុលំនៅឋាន

**២០១៥**

### ២០១៣-២០១៥

- រៀបចំកម្មវិធី Cambodia Big Build លើកទី២ (១១ ប្រទេសជាមួយអ្នកស្ម័គ្រចិត្តអន្តរជាតិចំនួន ២៦០ នាក់)
- គាំទ្រគ្រួសារជាង ១០០,០០០គ្រួសារ
- អនុវត្តវិធីសាស្ត្រ PASSA

**២០១៧**

### ២០១៦-២០១៧

- សហការរៀបចំវេទិកាលំនៅឋានថ្នាក់ជាតិលើកទីមួយជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងមានការចូលរួមពីភាគីពាក់ព័ន្ធចំនួន ៣១០នាក់
- គាំទ្រគ្រួសារជាង ១៨,០០០គ្រួសារ
- ស្វាគមន៍អ្នកស្ម័គ្រចិត្តអន្តរជាតិជាង ៧,០០០នាក់

**២០២០**

### ២០១៨-២០២០

- ណែនាំលំនៅឋានធន់នឹងអាកាសធាតុ
- ការផ្ទុះឡើងនៃជំងឺកូវីដ-១៩

**២០២៣**

### ២០២១-២០២៣

- បញ្ចប់គម្រោងលំនៅឋានសង្គមនៅខេត្តសៀមរាប និងខេត្តបាត់ដំបង (២,១ ហិកតានៅខេត្តសៀមរាប និង ០,៥ ហិកតានៅខេត្តបាត់ដំបង។ ការងារសរុបមានតម្លៃ ៦លានដុល្លារអាមេរិកសម្រាប់ដី និងហេដ្ឋារចនាសម្ព័ន្ធពីរដ្ឋាភិបាលជាតិ និង ៣,៥លានដុល្លារអាមេរិកពីអ្នកទទួលផលសហគមន៍ និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ)

**២០២៥**

### ២០២៤-២០២៥

- គាំទ្រគ្រួសារជាង ១៨៨,០០០គ្រួសារ
- ស្វាគមន៍អ្នកស្ម័គ្រចិត្តអន្តរជាតិជាង ១០,៧០០នាក់
- បង្កើតកិច្ចសម្របសម្រួលដល់ការបង្កើតបណ្តាញអង្គការមិនមែនរដ្ឋាភិបាលវិស័យលំនៅឋានកម្ពុជា

# ៤.២. ចំណុចសំខាន់ៗក្នុងឆ្នាំសារពើពន្ធ២០២៥៖ គ្រួសារ និងអ្នកទទួលផល

គិតត្រឹមឆ្នាំសារពើពន្ធ២០២៥ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានជួយគាំទ្រ ដល់ ១៨៨,០០០ គ្រួសារក្នុងការលើកកម្ពស់ជីវភាពរបស់ពួកគាត់តាមរយៈការសាងសង់លំនៅឋាន បរិក្ខារទឹកស្អាត និងអនាម័យ និងកម្មវិធីអភិវឌ្ឍសហគមន៍។

**ជំនួយផ្នែកលំនៅឋាន**

**៣៤៤** លំនៅឋានសរុប

- **១១៦** សាងសង់លំនៅឋានថ្មី
- **១៨៧** បានជួសជុលលំនៅឋាន
- **៤១** កែលម្អលំនៅឋាន

**បរិក្ខារទឹកស្អាត និងអនាម័យ**

**១៦២** បរិក្ខារ

**១៨៨,០០០** ការលើកកម្ពស់ជីវភាពគ្រួសារ



# ៤.៣. អន្តរាគមន៍ស្របនឹងអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា

ដោយផ្អែកលើចក្ខុវិស័យថា "ពិភពលោកមួយដែលមនុស្សគ្រប់គ្នាមានកន្លែងសមរម្យសម្រាប់រស់នៅ" អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានសហការជាមួយដៃគូក្នុងវិស័យលំនៅឋាន និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានលំនៅឋានរស់នៅសម្រាប់គ្រួសារងាយរងគ្រោះ និងគ្រួសារមានប្រាក់ចំណូលទាប។ ពួកយើងអនុវត្តកិច្ចការងារស្របតាមតម្រូវការអាទិភាព និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា៖

- យុទ្ធសាស្ត្របញ្ចកោណ – ដំណាក់កាលទី ១
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០២៤-២០២៨
- គោលនយោបាយជាតិស្តីពីលំនៅឋាន ឆ្នាំ ២០១៤
- សារាចរលេខ ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន ឆ្នាំ ២០១០
- គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ (គោលនយោបាយស្តីពីលំនៅឋានតម្លៃសមរម្យ) ឆ្នាំ ២០១៧
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) (ឆ្នាំ ២០២៤-២០២៨)
- ផែនការសកម្មភាពជាតិស្តីពីប្រព័ន្ធត្រជាក់
- ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០២៤-២០៣៥
- នារីរតនៈទី ៦ ផែនការយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ឆ្នាំ ២០២៤-២០២៨
- ច្បាប់ស្តីពីការលើកកម្ពស់សិទ្ធិជនមានពិការភាព
- សារាចរលេខ ០២សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច
- អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ស្តីពីចំណាត់ថ្នាក់ដីធ្លី
- ច្បាប់ភូមិបាល ឆ្នាំ ២០០១

# ៥ សមិទ្ធផលសំខាន់ៗនៃកម្មវិធី

## ៥.១. កម្មវិធីសាងសង់លំនៅឋានប្រកបដោយភាពធន់

**ការពង្រឹងការសាងសង់លំនៅឋានដែលធន់នឹងអាកាសធាតុតាមរយៈការរចនាប្រព័ន្ធត្រជាក់អកម្ម៖** អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានបង្ហាញពីភាពជាអ្នកដឹកនាំដ៏រឹងមាំក្នុងការជំរុញឱ្យមានដំណោះស្រាយលំនៅឋានដែលធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់គ្រួសារងាយរងគ្រោះ។ យោងតាមការវាយតម្លៃនាពេលថ្មីៗនេះបានបង្ហាញថា ការសាងសង់លំនៅឋានដោយប្រើប្រាស់មុខងារប្រព័ន្ធត្រជាក់អកម្មដូចជា ប្រព័ន្ធខ្យល់ចេញចូល ដំបូលការពារកម្តៅ ដំបូលអ៊ីសូឡង់ និងសំយ៉ាបផ្ទះ ដែលបានធ្វើឱ្យទីធ្លាខាងក្នុងផ្ទះមានសីតុណ្ហភាពត្រជាក់ជាងទីធ្លាខាងក្រៅផ្ទះជាមធ្យមចំនួន ៤,៦អង្សាសេ ឬអាចឈានដល់ ៦អង្សាសេនៅកន្លែងមួយចំនួនផងដែរ។ ការកែលម្អទាំងនេះបានកាត់បន្ថយភាពតានតឹងកើតឡើងដោយសារកម្តៅ និងកាត់បន្ថយការប្រើកង្ហារបានចំនួន ១៨ ភាគរយ ក្នុងអំឡុងរដូវប្រាំងដែលមានកម្តៅក្តៅខ្លាំង។ អ្នកទទួលផលបានរាយការណ៍ថា ស្ថានភាពរស់នៅរបស់ពួកគេមានភាពល្អប្រសើរជាងមុន ជាពិសេសការរស់នៅក្នុងផ្ទះដែលបានរចនាឱ្យមានប្រព័ន្ធខ្យល់ចេញចូល និងប្រព័ន្ធអ៊ីសូឡង់កម្តៅត្រឹមត្រូវ។

ការរចនាលំនៅឋាននេះផ្តល់ជូននូវផ្ទះដែលមានគុណភាពល្អរួមជាមួយនឹងតម្លៃដ៏សមរម្យ។ ផ្ទះនីមួយៗត្រូវបានសាងសង់ក្នុងតម្លៃជាមធ្យមចំនួន ៣.៥០០ដុល្លារអាមេរិក ហើយមានភ្ជាប់មកជាមួយប្រព័ន្ធត្រជាក់អកម្ម និងការតុបតែងលម្អផ្នែកខាងក្នុងមូលដ្ឋាន។ ការសន្សំសំចៃថាមពលប្រចាំឆ្នាំ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១៧.២៨០ kWh សម្រាប់គ្រួសារសរុបចំនួន ៩៦០គ្រួសារ ហើយនាំឱ្យកាត់បន្ថយការបញ្ចេញឧស្ម័ន $CO_2$ ប្រមាណ ១១៧,៥ តោនក្នុងមួយឆ្នាំ។ តួលេខនេះបង្ហាញថា ការរចនាលំនៅឋានប្រកបដោយនិរន្តរភាពអាចសាងសង់បានក្នុងតម្លៃសមរម្យ ដោយមិនធ្វើឱ្យបាត់បង់ផាសុកភាព និងសមត្ថភាពប្រើប្រាស់ឡើយ។ សម្ភារៈដែលបានប្រើប្រាស់ក្នុងគម្រោងសាងសង់លំនៅឋាន រួមមាន ពិដានក្តារបន្ទះស៊ីម៉ង់ត៍ (Shera) និងដំបូលលោហៈស្រោបដោយថ្នាំការពារកម្តៅ ដែលធន់ និងសមស្របយ៉ាងខ្លាំងជាមួយអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។ក្តារបន្ទះស៊ីម៉ង់ត៍(Shera)មានសមត្ថភាពផ្លាតពន្លឺព្រះអាទិត្យបានរហូតដល់ ៧៥ ភាគរយ ក្រោយពេលប្រើប្រាស់ហាលភ្លៀងអស់ពីររដូវកាល បង្ហាញឱ្យឃើញថាវាមានភាពធន់ទៅនឹងអាកាសធាតុយ៉ាងខ្លាំង។ការអាចផ្លាតពន្លឺព្រះអាទិត្យគឺជាលក្ខណៈដ៏ពិសេសមួយរបស់ផ្នែផលិតផលនេះ ដែលវាផ្លាតកម្តៅព្រះអាទិត្យចេញជាជាងស្រូបកម្តៅចូលក្នុងផ្ទះ។ ក្នុងការរចនា និងសាងសង់លំនៅឋាន ការការពារកម្តៅព្រះអាទិត្យគឺជាកត្តាដ៏សំខាន់មួយក្នុងការកាត់បន្ថយការស្រូបយកកម្តៅ និងធ្វើឱ្យសីតុណ្ហភាពក្នុងផ្ទះមានភាពត្រជាក់ប្រកបដោយផាសុកភាព។ក្រៅពីនេះ ការផ្តោតលើការរក្សាតម្លៃសមរម្យ របស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានធានាថា ប្រជាជនដែលងាយរងគ្រោះមានលទ្ធភាពទទួលបានការកែលម្អលំនៅឋានដោយមិនមានបញ្ហាផ្នែកហិរញ្ញវត្ថុ ធ្វើឱ្យកម្មវិធីនេះមានសារៈសំខាន់ចំពោះទាំងផ្នែកសង្គម និងវិស័យបរិស្ថាន។



**៩៦០**
**គ្រួសារ**

**ការលើកកម្ពស់ជីវភាព និងស្ថិរភាពហិរញ្ញវត្ថុតាមរយៈជំនួយខ្នាតតូច៖** ចាប់តាំងពីឆ្នាំ២០១៣មក អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបានផ្តល់ជំនួយខ្នាតតូចដល់គ្រួសារចំនួន ៣៥៤ គ្រួសារ។ កម្មវិធីជំនួយខ្នាតតូចសម្រាប់ជីវភាពរស់នៅតាមផ្ទះមិនត្រឹមតែផ្តល់នូវមូលនិធិសម្រាប់ប្រកបអាជីវកម្មប៉ុណ្ណោះទេ តែថែមទាំងជួយបង្កើនភាពធន់ សេចក្តីថ្លៃថ្នូរ និងឱកាសអភិវឌ្ឍន៍ដល់គ្រួសារដែលងាយរងគ្រោះផងដែរ។ កម្មវិធីនេះមានគោលបំណងគាំទ្រគ្រួសារនានាក្នុងការចូលរួម ឬពង្រឹងសកម្មភាពជីវភាពរស់នៅរបស់ពួកគេ រួមទាំងការងារកសិកម្ម និងការងារមិនមែនកសិកម្មផងដែរ។ កម្មវិធីនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់អាទិភាពដល់ក្រុមមនុស្សងាយរងគ្រោះ ដូចជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ជនមានពិការភាព មនុស្សចាស់ និងគ្រួសារដែលមានយុវជនជាមេគ្រួសារ។

ការរកឃើញសំខាន់ៗពីការវាយតម្លៃរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបង្ហាញថា ជំនួយខ្នាតតូចសម្រាប់ជីវភាពរស់នៅតាមផ្ទះ បានចូលរួមចំណែកក្នុងការបង្កើនប្រាក់ចំណូលគ្រួសារ កែលម្អស្ថានភាពលំនៅឋាន និងបង្កើនការឯករាជ្យលើខ្លួនឯង និងទំនុកចិត្តរបស់អ្នកទទួលផល។ ជាក់ស្តែង ជំនួយខ្នាតតូចទាំងនេះអាចឱ្យគ្រួសារចាប់ផ្តើម ឬពង្រីកអាជីវកម្មខ្នាតតូចរបស់ពួកគេ ដើម្បីរកប្រាក់ចំណូលបានកាន់តែច្រើន និងមានស្ថិរភាព។ អ្នកទទួលផលជាច្រើនបានរាយការណ៍ថា ពួកគេអាចមានលទ្ធភាពទិញ ទំនិញ និងប្រើប្រាស់សេវាកម្មសំខាន់ៗដូចជា អាហារ ថ្នាំពេទ្យ និងសម្ភារៈសិក្សា ស្របពេលដែលពួកគេបានកាត់បន្ថយការពឹងផ្អែកលើការខ្ចីប្រាក់។ កម្មវិធីនេះក៏បានបង្ហាញពីផលជះវិជ្ជមានលើការលើកកម្ពស់សមភាពយេនឌ័រផងដែរ។ ស្ត្រីជាច្រើនរូបបានរាយការណ៍ថា ពួកគេមានទំនុកចិត្តខ្ពស់ក្នុងការគ្រប់គ្រងថវិកា និងការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ។ លើសពីទៅទៀតនេះ គ្រួសារថែមទាំងមានសមត្ថភាពរៀបចំផែនការ និងគ្រប់គ្រងថវិការបស់ខ្លួនបានល្អប្រសើរជាងមុន ដែលសបញ្ជាក់ឱ្យឃើញពីតួនាទីរបស់គម្រោងក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ សមត្ថភាពគ្រប់គ្រងធនធានបានយ៉ាងមានប្រសិទ្ធភាពនេះ គឺជាកត្តាសំខាន់មួយក្នុងការកសាងភាពធន់រយៈពេលវែង។



## ការលើកកម្ពស់សមភាពយេនឌ័រតាមរយៈជំនួយផ្នែកលំនៅឋាន៖

លំនៅឋានមានសុវត្ថិភាព មិនមែនគ្រាន់តែជាបន្ទប់ដែលមានជញ្ជាំងបួនជ្រុង និងដំបូលនោះទេវាគឺជាកាតាលីករសម្រាប់សេចក្តីថ្លៃថ្នូរ សមភាព និងឱកាស។ តាមរយៈជំនួយផ្នែកលំនៅឋាន អង្គការលំនៅឋានមនុស្សជាតិកម្ពុជាបន្តបង្កើតផលជះវិជ្ជមានដល់ស្ត្រីក្នុងវិស័យសុខាភិបាល អប់រំ ជីវភាព និងការចូលរួមក្នុងសហគមន៍។ យោងតាមការវាយតម្លៃដែលបានធ្វើឡើងដោយអង្គការលំនៅឋានមនុស្សជាតិកម្ពុជានាពេលថ្មីៗនេះបានបង្ហាញឱ្យឃើញថាការមានលំនៅឋានដែលមានសុវត្ថិភាព រួមផ្សំជាមួយនឹងជំនួយជាថវិកា និងសកម្មភាពបណ្ដុះបណ្ដាលរបស់គម្រោងអាចឱ្យគ្រួសារនានាចាប់ផ្ដើមប្រកបអាជីវកម្មលក្ខណៈគ្រួសារ និងជួយធ្វើឱ្យស្ត្រីមានឥទ្ធិពលផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំង នៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

តួនាទីយេនឌ័រក៏មានការផ្លាស់ប្ដូរដ៏គួរឱ្យកត់សម្គាល់ផងដែរ ដោយសារបុរស និងស្ត្រីចេះចែករំលែកកិច្ចការផ្ទះជាមួយគ្នា ធ្វើឱ្យពួកគេមានពេលវេលាគ្រប់គ្រាន់សម្រាប់ផ្ដោតលើការលើកកម្ពស់ជីវភាពរបស់ខ្លួន។ តាមរយៈការផ្ដល់ជំនួយហិរញ្ញវត្ថុដើម្បីជួយស្ត្រីចាប់ផ្ដើមអាជីវកម្មលក្ខណៈគ្រួសារ វគ្គបណ្ដុះបណ្ដាលផ្នែកកសិកម្ម (ដូចជាការចិញ្ចឹមសត្វ និងដាំបន្លែ) និងការចូលរួមជាមួយស្ថាប័នសន្សំក្នុងស្រុកបានលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងការកែលម្អស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់ខ្លួនយ៉ាងខ្លាំង។ ជារួម ការផ្ដោតលើការពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី តាមរយៈមូលនិធិជំនួយចាប់ផ្ដើមអាជីវកម្ម រួមជាមួយនឹងការជួសជុល ឬសាងសង់លំនៅឋានថ្មី និងសកម្មភាពលើកកម្ពស់សមភាពយេនឌ័របានជួយឱ្យស្ត្រីអាចគ្រប់គ្រងជីវិតរបស់ខ្លួនបានកាន់តែប្រសើរ។



“ មុនពេលទទួលបានជំនួយខ្នាតតូចសម្រាប់ទ្រទ្រង់ជីវភាពនេះ ខ្ញុំគ្រាន់តែជាមេផ្ទះម្នាក់តែប៉ុណ្ណោះ។
ឥឡូវនេះ ខ្ញុំអាចធ្វើសេចក្តីសម្រេចចិត្តអំពីហិរញ្ញវត្ថុគ្រួសារ និងជួយបង់ថ្លៃសិក្សារបស់កូន។ខ្ញុំបានផងដែរ។ ”
- អ្នកទទួលផលម្នាក់រូបនៅខេត្តបាត់ដំបង

# ករណីសិក្សា

## វិថីឆ្ពោះទៅរកជីវភាពរស់នៅប្រកបដោយនិរន្តភាព – ដំណើរឆ្ពោះទៅកាន់ស្ថិរភាពរបស់ស្រីនី

ស្រីនី មានអាយុ ៣៨ ឆ្នាំ រស់នៅភូមិជ្រោយដង ខេត្តកណ្ដាល។ គាត់តែងតែភ្ញាក់ពីដំណេកដោយមានការព្រួយបារម្ភជារៀងរាល់ព្រឹក ព្រោះគាត់មិនដឹងច្បាស់ថាខ្លួនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីមកចិញ្ចឹមកូនៗបានឬក៏អត់។ អស់រយៈពេលជាច្រើនឆ្នាំមកហើយការនេសាទគឺជាប្រភពចំណូលតែមួយគត់របស់គ្រួសារគាត់។ ការនេសាទគឺជារបរដែលពិបាកទាយទុកជាមុនប្រើកម្លាំងច្រើន ហើយរបរនេះពឹងផ្អែកលើអាកាសធាតុទាំងស្រុង។ ថ្ងៃខ្លះគាត់អាចរកចំណូលបានប្រហែល ៥ដុល្លារក្នុងមួយថ្ងៃ។ តែនៅថ្ងៃខ្លះទៀត គាត់រកចំណូលមិនបានទាល់តែសោះ។

ស្រីនី មានកូនប្រាំពីរនាក់។ គាត់រស់នៅជាមួយស្វាមី និងកូនៗរបស់គាត់នៅក្នុងផ្ទះទ្រុឌទ្រោមមួយដែលសង់ពីសន្លឹកស័ង្កសីចាស់ៗ។

ពេលភ្លៀងធ្លាក់ម្ដងៗ ទឹកភ្លៀងតែងតែលេចចូលផ្ទះតាមដំបូល ធ្វើឱ្យភួយរបស់ពួកគេសើមអស់។ ដូច្នេះហើយ ដើម្បីការពារកុំឱ្យទទឹកនៅពេលយប់ ពួកគេត្រូវដណ្ដប់ថង់ប្លាស្ទិក។ ដោយសារពួកគេគ្មានប្រភពចំណូលផ្សេងទៀត គ្មានទ្រព្យសម្បត្តិ និងគ្មានសមត្ថភាពរៀបចំផែនការលើសពីការប្រឹងរស់រានមានជីវិតស្រីនីតែងតែរស់នៅក្នុងភាពអស្ថិរភាពឥតឈប់ឈរ។

ការផ្លាស់ប្ដូរចាប់ផ្ដើមកើតមានឡើងនៅពេលគាត់បានស្គាល់អំពីកម្មវិធីរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា។ ក្រោយមក គាត់ទទួលបានលំនៅឋានដ៏សមរម្យមួយជាជំនួយ រួមជាមួយនឹងមូលនិធិជំនួយខ្នាតតូចសម្រាប់ទ្រទ្រង់ជីវភាព។ គាត់បាននិយាយថា “វាប្រៀបបានដូចជាការចាប់ផ្ដើមជាថ្មីអ៊ីចឹង។ វាជាលើកដំបូងហើយដែលខ្ញុំអាចគិតអំពីអនាគតរបស់ខ្លួនក្រៅពីការប្រឹងតែរស់រានមានជីវិត”។

ផ្ទះថ្មីរបស់គាត់បានសាងសង់ឡើងដោយមានភាពធន់នឹងទឹកជំនន់ មានជញ្ជាំង និងដំបូលរឹងមាំ។ នៅក្នុងយប់ដំបូងក្នុងផ្ទះថ្មី គាត់ដេកមិនលក់ទាល់តែសោះ។ នេះមិនមែនដោយសារតែការព្រួយបារម្ភនោះទេ ប៉ុន្តែដោយសារតែអារម្មណ៍ធូរស្រាល។

បន្ទាប់ពីទទួលបានផ្ទះថ្មី និងជំនួយខ្នាតតូចសម្រាប់ទ្រទ្រង់ជីវភាពចំនួន ៣០០ដុល្លារ ពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ស្រីនីបានធ្វើការសម្រេចចិត្តដ៏ធំមួយគឺបើកអាជីវកម្មចិញ្ចឹមមាន់ខ្នាតតូចមួយ។ គាត់បាននិយាយថា៖ “ខ្ញុំមិនមានបទពិសោធន៍ឡើយ ប៉ុន្តែខ្ញុំត្រៀមខ្លួននឹងរៀន!”។ ក្រុមការងាររបស់អង្គការលំនៅឋានមនុស្សជាតិបានផ្ដល់ការបណ្ដុះបណ្ដាលអាជីវកម្មមូលដ្ឋានមួយចំនួនដូចជា៖ ការគ្រប់គ្រងថវិកា ការធ្វើផែនការវិនិយោគ និងការកត់ត្រាបញ្ជីគណនេយ្យ មុនពេលគាត់ចាប់ផ្ដើមចិញ្ចឹមមាន់។

សព្វថ្ងៃនេះចំណូលរបស់ស្រីនីបានកើនឡើងលើសទ្វេដង។ គាត់នៅតែបន្តនេសាទ ប៉ុន្តែឥឡូវនេះ គាត់អាចរកប្រាក់ចំណូលបានពី ១០–១៥ ដុល្លារក្នុងមួយថ្ងៃ និងបន្ថែមប្រហែល ៥០ ដុល្លារទៀតក្នុងមួយខែពីការលក់មាន់ នៅពេលមានតម្រូវការខ្ពស់។ អាជីវកម្មរបស់គាត់រីកចម្រើនជាលំដាប់ជារៀងរាល់ខែ។ គាត់បានយកប្រាក់ចំណេញទៅទិញចំណីសត្វបន្ថែម បង្កើនចំនួនមាន់ និងចាប់ផ្ដើមកែលម្អផ្ទះបន្តិចម្ដងៗ។ អ្វីដែលសំខាន់បំផុតនោះគឺ នាងអាចឱ្យកូនៗបន្តការសិក្សា ទិញថ្នាំព្យាបាលនៅពេលឈឺថ្កាត់ និងផ្គត់ផ្គង់អាហារឱ្យគ្រួសារបានរៀងរាល់ថ្ងៃ។ “ខ្ញុំអាចដេកលក់ស្រួល ព្រោះខ្ញុំដឹងថាកូនៗរបស់ខ្ញុំនឹងមានអាហារញ៉ាំគ្រប់គ្រាន់នៅថ្ងៃស្អែក។”

គោលដៅរបស់ ស្រីនី មានភាពសាមញ្ញ ប៉ុន្តែមានអត្ថន័យយ៉ាងខ្លាំង។ គាត់ចង់ចិញ្ចឹមមាន់ឱ្យបានច្រើនជាងមុន បន្តកែលម្អលំនៅឋាន និងចង់ឃើញកូនៗរបស់នាងទាំងអស់បញ្ចប់ការសិក្សាដោយគ្មានឧបសគ្គ។ “គម្រោងនេះបានជួយខ្ញុំដោះស្រាយបញ្ហាជាច្រើន។ ឥឡូវ ខ្ញុំរឹងមាំជាងមុន ហើយខ្ញុំមានក្តីសង្ឃឹម។”



# ៥.២. កម្មវិធីពង្រឹងអភិបាលកិច្ចលំនៅឋាន និងប្រព័ន្ធគោលនយោបាយលំនៅឋាន

**ការបង្កើតបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលវិស័យលំនៅឋានកម្ពុជា៖** ក្រោមកិច្ចសហប្រតិបត្តិការជាមួយ UN-Habitat និងអគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានចូលរួមដឹកនាំក្នុងការបង្កើតបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលវិស័យលំនៅឋានកម្ពុជា ដែលបានទទួលស្គាល់ជាផ្លូវការដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០២៥។

បណ្ដាញនេះផ្ដល់ជាវេទិកាសហការសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យលំនៅឋានតម្លៃសមរម្យ ដើម្បីសម្របសម្រួល ចែករំលែកចំណេះដឹង និងការស្វែងរកការគាំទ្ររួមគ្នា។ គោលបំណងស្នូលរបស់បណ្ដាញនេះ រួមមានការលើកកម្ពស់ការអនុវត្តល្អបំផុត ការបង្កើតផលជះវិជ្ជមានដល់ការរៀបចំគោលនយោបាយ ការលើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រ និងការពង្រឹងសមត្ថភាពរបស់អង្គការដែលផ្ដោតលើវិស័យលំនៅឋាន។ មកដល់ពេលបច្ចុប្បន្ន មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៥ អង្គការបានចូលរួមជាសមាជិកនៃបណ្ដាញនេះ ហើយសមាជិកជាច្រើនទៀតដែលរំពឹងថានឹងចូលរួមនៅឆ្នាំក្រោយៗ។ គំនិតផ្ដួចផ្ដើមនេះ តំណាងឱ្យសមិទ្ធផលដ៏សំខាន់មួយ ក្នុងការជំរុញការខិតខំប្រឹងប្រែងរួមគ្នា ដើម្បីកែលម្អលក្ខណៈលំនៅឋានសម្រាប់ប្រជាជនដែលរកប្រាក់ចំណូលបានទាប និងប្រជាជនដែលងាយរងគ្រោះទូទាំងប្រទេសកម្ពុជា។

**១៥ អង្គការ**
**បានចូលរួម ក្នុងបណ្ដាញ**




អង្គការលំនៅឋានកម្ពុជាបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស




ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់


Presided Over by H.E. Seng Thany, Under Secretary
ANGKOR ERA HOTEL
12 March 2025



**លំនៅឋានក្នុងក្របខណ្ឌគាំពារសង្គម៖** ចាប់តាំងពីដើមឆ្នាំ ២០២៤ មក អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០២៤-២០៣៥។ តាមរយៈការចូលរួមយ៉ាងសកម្មក្នុងក្រុមការងារបច្ចេកទេស ការត្រួតពិនិត្យលើសេចក្តីព្រាងគោលនយោបាយ និងការតស៊ូមតិជាបន្តបន្ទាប់ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានដាក់បញ្ចូលបញ្ហាលំនៅឋានទៅក្នុង**ផ្នែក ៣.៦ ស្តីពីភាពគ្មានជម្រកនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម**។ នេះជាការផ្លាស់ប្តូរដ៏ធំមួយបើធៀបទៅនឹងក្របខណ្ឌចាស់ ដែលមិនមានរួមបញ្ចូលបញ្ហាលំនៅឋាន។ គោលនយោបាយនេះ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅខែកុម្ភៈ ឆ្នាំ ២០២៥ ហើយបច្ចុប្បន្នបានទទួលស្គាល់លំនៅឋានមានតម្លៃសមរម្យ មានសុវត្ថិភាព និងមានគុណភាពជាផ្នែកមួយនៃប្រព័ន្ធគាំពារសង្គមជាតិ។



៣.៦. ភាពគ្មានជម្រក

៣.៦.១. ស្ថានភាពទូទៅ

ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងគម្លាតនៃការអភិវឌ្ឍរវាងទីក្រុង និងជនបទ បានជំរុញឱ្យពលរដ្ឋកម្ពុជាធ្វើការផ្លាស់ទីលំនៅទៅកាន់តំបន់ដែលមានការអភិវឌ្ឍខ្ពស់ជាង ដើម្បីស្វែងរកឱកាសការងារ និងការសិក្សា។ ការណ៍នេះ បានធ្វើឱ្យពលរដ្ឋទាំងនោះ ជាពិសេសពលរដ្ឋដែលមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ប្រឈមនឹងបញ្ហានៃការរកជម្រកសមរម្យដើម្បីស្នាក់អាស្រ័យ ដែលជាឧបសគ្គមួយនាំឱ្យមានការបោះបង់ការសិក្សាទៀតផង។ ទន្ទឹមនេះ, ពលរដ្ឋដែលមានចំណូលទាបក៏កំពុងប្រឈមនឹងបញ្ហានៃការទទួលបានលំនៅឋានសមរម្យផ្ទាល់ខ្លួនផងដែរ ដោយសារថ្លៃផ្ទះសម្បែងមានការកើនឡើងជាតំហុកជាពិសេសក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។កន្លងមក,រាជរដ្ឋាភិបាលបានដាក់ចេញនូវគម្រោង "លំនៅឋានតម្លៃសមរម្យ - Affordable Housing" ប៉ុន្តែគំនិតផ្តួចផ្តើមនេះ មិនទាន់មានវិសាលភាពទូលំទូលាយ និងមិនទាន់ត្រូវបានចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធគាំពារសង្គមនៅឡើយ។

៣.៦.២. វិធានការគោលនយោបាយ

រាជរដ្ឋាភិបាលបាន និងកំពុងផ្តល់ការយកចិត្តទុកដាក់ដល់ក្រុមពលរដ្ឋគោលដៅមួយចំនួនតាមរយៈអន្តរាគមន៍ ដែលរួមមានការគិតគូរពីការឧបត្ថម្ភឈ្នួលផ្ទះ, ការបញ្ចុះថ្លៃទឹកស្អាត និងថ្លៃអគ្គិសនីឱ្យនៅក្នុងអត្រាទាប ជាពិសេសសម្រាប់កម្មករនិយោជិតរោងចក្រដែលជួលបន្ទប់ស្នាក់នៅជាដើម។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពក្នុងការផ្តល់ការគាំទ្រផ្នែកលំនៅឋាន តាមរយៈយន្តការគាំពារសង្គម ដោយធ្វើការសិក្សាសមិទ្ធិលទ្ធភាព ក្នុងការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ទ្រទ្រង់ចំណាយជួលផ្ទះបន្ទប់ស្នាក់នៅជូនដល់សិស្សនិងនិស្សិតដែលមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យដោយអាចចាប់ផ្តើមសាកល្បងនៅតំបន់ទីប្រជុំជនមួយចំនួន មុននឹងពង្រីកវិសាលភាពទៅទូទាំងប្រទេស។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល ក៏នឹងធ្វើការសិក្សាសមិទ្ធិលទ្ធភាពក្នុងការដាក់ឱ្យដំណើរការកម្មវិធី "លំនៅឋានតម្លៃសមរម្យ" ក្នុងគោលបំណង ផ្តល់លទ្ធភាពជូនពលរដ្ឋដែលមានចំណូលទាប និងជនងាយរងគ្រោះរួមទាំងអ្នកទទួលផលក្រោមកម្មវិធីជាតិជំនួយសង្គម ដើម្បីទទួលបានផ្ទះសម្បែងរស់នៅសមរម្យ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏នឹងសិក្សាសមិទ្ធិលទ្ធភាពក្នុងការផ្តល់ការគាំទ្រសម្រាប់ជួយសម្រួលដល់ក្រុមជនងាយរងគ្រោះដែលកំពុងស្នាក់នៅតាមទីវត្តអារាម និងទីកន្លែងសាសនាដទៃទៀត ផងដែរ។



**ការអភិវឌ្ឍដឹកនាំដោយសហគមន៍តាមរយៈវិធីសាស្ត្រប៉ាសា៖** នៅឆ្នាំសារពើពន្ធ២០២៥ អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានបន្តជំរុញការកសាងភាពធន់ដែលដឹកនាំដោយសហគមន៍តាមរយៈវិធីសាស្ត្រប៉ាន់ប្រមាណសុវត្ថិភាពលំនៅឋានតាមបែបចូលរួម (ប៉ាសា)។ យ៉ាងហោចណាស់មានក្រុមប៉ាសា ចំនួន ១៩ ក្រុម បានបង្កើតឡើង ដែលមានសមាជិកសរុបចំនួន ៣១៧ នាក់ (រួមមានស្ត្រីចំនួន ២១៧ នាក់) ហើយទទួលបានជំនួយពីមូលនិធិជំនួយខ្នាតតូចដែលដឹកនាំដោយសហគមន៍ចំនួន ៧។ ដើម្បីវាយតម្លៃផលជះរយៈពេលវែងនៃវិធីសាស្ត្រនេះរបស់គម្រោងពីមុនៗ និងគម្រោងនាពេលបច្ចុប្បន្ន អង្គការលំនៅឋានមនុស្សជាតិកម្ពុជា បានអនុវត្តការវាយតម្លៃផលជះរបស់ក្រុមប៉ាសាដ៏ទូលំទូលាយមួយក្នុងអំឡុងខែឧសភា ដល់ខែមិថុនា ឆ្នាំ ២០២៥ ដោយរាប់បញ្ចូលគម្រោងដែលបានអនុវត្តពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥។ លទ្ធផលនៃការវាយតម្លៃបានបញ្ជាក់ពីប្រសិទ្ធភាពរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា ក្នុងការផ្តល់ភាពអង់អាចដល់សហគមន៍ឱ្យអាចកំណត់ហានិភ័យ អភិវឌ្ឍដំណោះស្រាយ និងអនុវត្តវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ គម្រោងដឹកនាំដោយសហគមន៍សរុបចំនួន ៩៤ គម្រោងដែលបានបញ្ចប់ បានផ្តល់អត្ថប្រយោជន៍ដល់គ្រួសារចំនួន ១៨,២២៩ គ្រួសារតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដូចជា ផ្លូវថ្នល់ ប្រព័ន្ធលូ ភ្លើងបំភ្លឺផ្លូវដំណើរការដោយថាមពលព្រះអាទិត្យ និងលំនៅឋានដែលកាន់តែមានសុវត្ថិភាព។ បន្ថែមពីនេះ គ្រួសារចំនួន ២៦១ គ្រួសារ ទទួលបានការកែលម្អដោយផ្ទាល់លើជម្រករស់នៅ ប្រព័ន្ធទឹក អនាម័យ និងអគ្គិសនី។ អ្នកឆ្លើយតបចំនួន ៩៤ ភាគរយ បានបញ្ជាក់ថា សេចក្តីសម្រេចក្នុងវិធីសាស្ត្រប៉ាសាបានឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់សហគមន៍។ ការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តមានកម្រិតមធ្យមដល់ខ្ពស់ (៨៩ ភាគរយ) ហើយគ្រួសារដែលមានសមាជិកជាជនមានពិការភាពយ៉ាងហោចណាស់ ១៥ ភាគរយ មានអាទិភាពក្នុងការទទួលបានជំនួយផ្នែកលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ។ សកម្មភាពរបស់ក្រុមប៉ាសាត្រូវបានវាយតម្លៃថាមានប្រយោជន៍ខ្ពស់ចំពោះការត្រៀមខ្លួនទប់ស្កាត់គ្រោះមហន្តរាយ ដោយទទួលបានពិន្ទុ ៨,៧ លើ ១០ ហើយអ្នកឆ្លើយតបចំនួន ៦៩ភាគរយ បានវាយតម្លៃថា “មានប្រយោជន៍ខ្លាំងបំផុត”។ កម្រិតចំណេះដឹងមានការកើនឡើងយ៉ាងគួរឱ្យកត់សម្គាល់ ដោយមានអ្នកចូលរួម ចំនួន ៥៤,៣៣ ភាគរយ បានរាយការណ៍ថាពួកគេបានបង្កើនការយល់ដឹងអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការសម្របខ្លួនទៅនឹងអាកាសធាតុ និងអ្នកចូលរួមចំនួន ៧៣,២៣ ភាគរយទៀតបានចាប់ផ្តើមចាត់វិធានការកែលម្អសុវត្ថិភាពលំនៅឋានរបស់ខ្លួន។



**១៩ ក្រុមប៉ាសា**

ក្រុមដែលបានបង្កើតឡើង

**៣១៧ សមាជិក**

រួមមានស្ត្រី ២១៧នាក់

# ករណីសិក្សា

## ប៉ាសា បានផ្តល់ឱកាស និងធ្វើឱ្យជីវិតខ្ញុំមានភាពងាយស្រួល

នៅក្នុងខែធ្នូ ឆ្នាំ ២០២៤ អ្នកស្រី ហួរ មានអាយុ ៦៧ ឆ្នាំ ជាពលរដ្ឋម្នាក់រស់នៅក្នុងភូមិសែនរីករាយ១ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទទួលបានផ្ទះដែលត្រូវបានជួសជុលឡើងវិញទាំងស្រុង តាមរយៈគំនិតផ្តួចផ្តើមក្រុម ប៉ាសា។ មុនពេលជួសជុល គាត់បានរៀបរាប់អំពីស្ថានភាពរស់នៅរបស់ខ្លួនថា គ្មានសុវត្ថិភាព និងបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង។ គាត់បានរំលឹកថា៖ “នៅពេលរស់នៅក្នុងផ្ទះចាស់របស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាភ័យខ្លាចណាស់។ នៅពេលមានភ្លៀង ខ្ញុំភ័យខ្លាចថាលិចទឹក និងខ្យល់បក់ខ្លាំងៗដែលអាចធ្វើឱ្យផ្ទះបាក់ធ្លាក់មកលើខ្ញុំ។ ដំបូលផ្ទះខ្ញុំលេចទឹករហូត ហើយខ្យល់ដែលបក់មកខ្លាំងៗធ្វើឱ្យផ្ទះរង្គើ។ យើងបានយកសន្លឹកស័ង្កសីមកប្រក់ជាដំបូល ដើម្បីការពារខ្លួនពីទឹកភ្លៀង។”

អ្នកស្រី ហួរ បានពន្យល់ថា ផ្ទះរបស់គាត់មិនមានគ្រឹះរឹងមាំឡើយ ដោយសារសសរគ្រឹះមួយបានដួលរលំ។ ការភ័យខ្លាចអំពីការបាក់ផ្ទះធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពផ្លូវចិត្តរបស់គាត់។ គាត់បាននិយាយថា៖ “មុនពេលជួសជុល ខ្ញុំតែងតែមានភាពតានតឹង។ សូម្បីតែនៅពេលដែលខ្ញុំដេក ក៏ខ្ញុំគិតតែពីគ្រោះថ្នាក់ដែរ។ ទឹកភ្លៀងតែងតែលេចចូលមកក្នុងតាមដំបូល និងជញ្ជាំង។” ដោយមានការគាំទ្រពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ក្រុមប៉ាសាបានចុះទៅវាយតម្លៃស្ថានភាពផ្ទះរបស់គាត់ ហើយសម្រេចចិត្តផ្តល់ជំនួយដល់គាត់។ បន្ទាប់ពីការសម្ភាសន៍ជាមួយក្រុមគ្រួសាររួច គាត់ក៏ទទួលបានជំនួយតាមរយៈការជួសជុលផ្ទះឡើងវិញ។ អ្នកស្រីក៏បានចូលរួមចំណាយប្រាក់ចំនួន ៣៥០ ដុល្លារអាមេរិក សម្រាប់បន្ថែមក្នុងការជួសជុលផ្ទះនេះផងដែរ ដែលនេះបង្ហាញពីការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវរបស់គាត់។

អ្នកស្រី ហួរ បានរៀបរាប់ពីអារម្មណ៍របស់ខ្លួនថា៖ “ឥឡូវនេះ ខ្ញុំសប្បាយចិត្តណាស់ ហើយលែងមានភាពភ័យខ្លាចតទៅទៀតហើយ។ ខ្ញុំលែងមានភាពតានតឹងហើយ ថ្វីបើខ្ញុំនៅជំពាក់បំណុលអ្នកដទៃក៏ពិតមែន តែខ្ញុំមានភាពតានតឹងរបៀបផ្សេង ដែលវាមិនសូវខ្លាំងដូចការភ័យខ្លាចដែលខ្ញុំធ្លាប់មានកាលពីមុនទេ។ ឥឡូវនេះ ខ្ញុំអាចផ្តោតលើការរកប្រាក់សងបំណុលគេដោយមិនចាំបាច់បារម្ភពីសុវត្ថិភាពរបស់ខ្លួនទៀតឡើយ។”

រឿងរ៉ាវរបស់អ្នកស្រី ហួរ បង្ហាញឱ្យឃើញថា គម្រោង ប៉ាសា មិនត្រឹមតែបានធ្វើឱ្យស្ថានភាពរស់នៅផ្លូវកាយរបស់គាត់មានភាពប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកកម្ពស់សុខុមាលភាពផ្លូវចិត្ត និងអារម្មណ៍មានសុវត្ថិភាពរបស់គាត់ផងដែរ។



“ ឥឡូវនេះ ខ្ញុំសប្បាយចិត្តណាស់ ហើយលែងមានភាពភ័យខ្លាចតទៅទៀតហើយ។ ខ្ញុំលែងមានភាពតានតឹងហើយ ថ្វីបើខ្ញុំនៅជំពាក់បំណុលអ្នកដទៃក៏ពិតមែន តែខ្ញុំមានភាពតានតឹងរបៀបផ្សេង ដែលវាមិនសូវខ្លាំងដូចការភ័យខ្លាចដែលខ្ញុំធ្លាប់មានកាលពីមុនទេ។ ឥឡូវនេះ ខ្ញុំអាចផ្តោតលើការរកប្រាក់សងបំណុលគេ ដោយមិនចាំបាច់បារម្ភពីសុវត្ថិភាពរបស់ខ្លួនទៀតឡើយ។ ”

# ការប្រមូលធនធានដឹកនាំដោយសហគមន៍ – ពីការរៀបចំផែនការរហូតដល់ការអនុវត្តគម្រោង

## ការប្រែក្លាយថវិកាចំនួន ៣,០០០ ដុល្លារទៅជាស្ពានសហគមន៍ដែលមានតម្លៃ ៣០,០០០ ដុល្លារ

សមិទ្ធផលដ៏គួរឱ្យកត់សម្គាល់បំផុតរបស់វិធីសាស្ត្រប៉ាសា គឺសមត្ថភាពក្នុងការផ្តល់ភាពអង់អាចដល់សហគមន៍ក្នុងការកំណត់អាទិភាពអភិវឌ្ឍរបស់ខ្លួន និងការប្រមូលធនធានដោយឯករាជ្យមកបំពេញតម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ទាន់។ តាមរយៈការធ្វើផែនការបែបចូលរួម និងការពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំ សហគមន៍មួយចំនួនបានបង្ហាញពីសមត្ថភាពដ៏លេចធ្លោក្នុងការអង្គាសប្រាក់ ការរៀបចំផែនការ និងការចរចា ដែលជាញឹកញាប់ទទួលបានចំនួនលើសពីថវិកាគម្រោងដើមទៅទៀត។

ក្រុមប៉ាសា នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង ដំបូងឡើយទទួលបានថវិកាជំនួយពីអង្គការលំនៅឋានមនុស្សជាតិកម្ពុជាសម្រាប់ការងារសហគមន៍ចំនួន ៣,០០០ ដុល្លារអាមេរិក ដើម្បីគាំទ្រដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ ពួកគេបានប្រើប្រាស់ឧបករណ៍រៀបចំផែនការបែបចូលរួមក្នុងវិធីសាស្ត្រប៉ាសាដើម្បីកំណត់ថ្លៃចំណាយជាក់ស្តែងសម្រាប់ការសាងសង់ស្ពានដែលត្រូវការជាចាំបាច់នេះ។ ដោយយល់ឃើញថាថវិកាដែលទទួលបានមានកម្រិតក្រុមប៉ាសា បានធ្វើការយ៉ាងសកម្មក្នុងការទាក់ទងទៅអាជ្ញាធរមូលដ្ឋាន ប្រជាជនក្នុងសហគមន៍ដែលមានជីវភាពធូរធារ និងភាគីពាក់ព័ន្ធផ្សេងៗទៀតដើម្បីបង្កើនទំហំថវិកា។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេទទួលបានផ្លែផ្កា ដោយក្រុមការងារប៉ាសាបានកៀរគរប្រាក់បន្ថែមចំនួន ២៧,០០០ ដុល្លារដោយជោគជ័យ ដែលធ្វើឱ្យថវិកាសរុបសម្រាប់ការសាងសង់ស្ពានកើនឡើងដល់ ៣០,០០០ ដុល្លារ។

សមិទ្ធផលដ៏គួរឱ្យកោតសរសើរនេះបង្ហាញឱ្យឃើញថា ការរៀបចំផែនការដឹកនាំដោយសហគមន៍ រួមជាមួយការយល់ដឹងច្បាស់អំពីគម្លាតថវិកា និងយុទ្ធសាស្ត្រក្នុងការប្រមូលធនធានអាចបង្កើតបានជាការចូលរួមចំណែកយ៉ាងសំខាន់ពីសហគមន៍មូលដ្ឋាន។

សមាជិកក្រុមប៉ាសា បានចូលរួមដោយផ្ទាល់ក្នុងការដឹកនាំដំណើរការរៀបចំផែនការ ការរៀបចំសំណើផែនការ ការកំណត់គម្លាតថវិកា និងការចូលរួមទាក់ទងជាមួយភាគីសំខាន់ៗប្រកបដោយទំនុកចិត្ត និងភាពច្បាស់លាស់ ។




សូមស្វាគមន៍

# ៥.៣. កម្មវិធីជម្រុញវឌ្ឍនភាពទីផ្សាលំនៅឋាន

## ៥,២៥៧ គ្រួសារ

គ្រួសារទទួលបានសេវាកម្មហិរញ្ញវត្ថុតាមរយៈ មូលនិធិ MicroBuild របស់ TCIS ក្នុងឆ្នាំ FY ២០២៥

## ១៦៧ នាក់ ចូលរួម

(ស្ត្រីចំនួន ១២៥ នាក់)

ការបញ្ចៀបចំណេះដឹងផ្នែកហិរញ្ញវត្ថុ

## ៥ ក្រុមសន្សំ

ត្រូវបានបង្កើតឡើងដោយមានសមាជិកសរុបចំនួន ៩៩ នាក់ (ស្ត្រីចំនួន ៨៥ នាក់)



# ៥.៤. ការងារស្ម័គ្រចិត្តសម្រាប់ការអភិវឌ្ឍសហគមន៍

**៧៤៩ (ស្ត្រីចំនួន ៣៧៩ នាក់)**

ចំនួនអ្នកស្ម័គ្រចិត្តសរុប

- **៥៦៥ នាក់ (ស្ត្រីចំនួន ២៦១ នាក់)**
  អ្នកស្ម័គ្រចិត្តអន្តរជាតិ

- **១៨៤ នាក់ (ស្ត្រីចំនួន ១១៨ នាក់)**
  អ្នកស្ម័គ្រចិត្តក្នុងស្រុក

**៤៣ ខ្នងផ្ទះ**

ដែលបានសាងសង់



# ពាក្យពេចន៍របស់អ្នកស្ម័គ្រចិត្តក្នុងស្រុក

នាងខ្ញុំឈ្មោះ ស៊ីម ច័ន្ទចរិយា។ ខ្ញុំមានអាយុ ២២ ឆ្នាំ និងជានិស្សិតឆ្នាំទី ៣ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ខ្ញុំបានស្ម័គ្រចិត្តធ្វើជាអ្នកបកប្រែជាមួយអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ចាប់តាំងពីឆ្នាំ ២០២៤ មកម្ល៉េះ ហើយលើកនេះជាការចូលរួមជាលើកទី ៤ របស់ ខ្ញុំ។

ការងារស្ម័គ្រចិត្តជាមួយអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ជួយឱ្យខ្ញុំអភិវឌ្ឍខ្លួនឯងបានជាច្រើនផ្នែក។ ខ្ញុំបានអនុវត្តភាសាអង់គ្លេសជាមួយអ្នកស្ម័គ្រចិត្តបរទេស ហើយក៏បានរៀនអំពីការងារសាងសង់មួយចំនួននៅទីតាំងសាងសង់លំនៅឋានផងដែរ។ ក្នុងនាមជាអ្នកបកប្រែឱ្យអង្គការលំនៅឋានមនុស្សជាតិកម្ពុជា ខ្ញុំបានយល់ដឹងអំពីជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍ក្រីក្រ។ ខ្ញុំបានរៀនអំពីរបៀបសាងសង់ផ្ទះ ធ្វើការជាមួយកម្មករជំនាញ និងឃើញថាការងារជាក្រុមអាចនាំឱ្យមានលទ្ធផលដ៏ល្អប្រសើរ។ ខ្ញុំក៏រីករាយក្នុងការចែករំលែកវប្បធម៌ និងស្វែងយល់អំពីប្រទេសផ្សេងៗ តាមរយៈការសន្ទនាជាមួយអ្នកស្ម័គ្រចិត្តដទៃទៀតផងដែរ។

ខាងក្រោមនេះជាមូលហេតុដែលខ្ញុំចង់ធ្វើជាអ្នកស្ម័គ្រចិត្តម្តងទៀត៖ ខ្ញុំធ្លាប់ធ្វើការជាមួយគ្រួសារមួយ ដែលផ្ទះរបស់ពួកគាត់តែងតែលេចទឹករាល់ពេលភ្លៀងធ្លាក់ម្តងៗ។ ស្ថានភាពនេះបានរំខានដល់ការគេង និងការសិក្សារបស់កូនៗរបស់ពួកគេ។ ក្នុងនាមជានិស្សិតមួយរូបដែលមានផ្ទះសមរម្យសម្រាប់រស់នៅ ខ្ញុំយល់ថា ផ្ទះដ៏សមរម្យមួយអាចជួយឱ្យកុមាររៀនសូត្របានល្អប្រសើរជាងមុន។ រឿងរ៉ាវរបស់ពួកគេបានជំរុញទឹកចិត្តខ្ញុំ និងធ្វើឱ្យខ្ញុំមានអំណរយ៉ាងខ្លាំងចំពោះការមានផ្ទះសមរម្យមួយសម្រាប់រស់នៅ។

អង្គការលំនៅឋានមនុស្សជាតិកម្ពុជា មិនត្រឹមតែសាងសង់លំនៅឋានតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសាងសង់ក្តីសង្ឃឹមសម្រាប់អនាគត ជាពិសេសសម្រាប់កុមារ។ ស្នាមញញឹមរបស់ម្ចាស់ផ្ទះ នៅពេលដែលពួកគេឃើញផ្ទះថ្មីរបស់ខ្លួន បានធ្វើឱ្យបេះដូងរបស់ខ្ញុំមានភាពកក់ក្តៅ។ ខ្ញុំមានសេចក្តីរីករាយណាស់ដែលបានក្លាយជាផ្នែកមួយនៃផលជះវិជ្ជមានដល់សហគមន៍។




“ក្នុងនាមជានិស្សិតមួយរូបដែលមានផ្ទះសមរម្យសម្រាប់រស់នៅ ខ្ញុំយល់ថា ផ្ទះដ៏សមរម្យមួយអាចជួយឱ្យកុមាររៀនសូត្របានល្អប្រសើរជាងមុន។ រឿងរ៉ាវរបស់ពួកគេបានជំរុញទឹកចិត្តខ្ញុំ និងធ្វើឱ្យខ្ញុំមានអំណរយ៉ាងខ្លាំងចំពោះការមានផ្ទះសមរម្យមួយសម្រាប់រស់នៅ។”

# ពាក្យពេចន៍របស់អ្នកស្ម័គ្រចិត្តអន្តរជាតិ

ខ្ញុំចូលចិត្តចូលរួមសាងសង់ជាមួយអង្គការលំនៅឋានមនុស្សជាតិណាស់។ ការស្ម័គ្រចិត្តចូលរួមសាងសង់នៅតាមប្រទេសនានាជុំវិញពិភពលោក គឺបានបំពេញបំណង និងដួងចិត្តរបស់ខ្ញុំ។ លើកនេះជាលើកទី ៤ ហើយ ដែលខ្ញុំបានស្ម័គ្រចិត្តចូលរួមសាងសង់នៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំនឹងបន្តចូលរួមជានិច្ច។ នៅពេលដែលខ្ញុំបានឃើញស្នាមញញឹមរបស់គ្រួសារ និងសមាជិកសហគមន៍ ព្រមទាំងដឹងថាខ្ញុំបានចូលរួមជាចំណែកតូចមួយក្នុងសកម្មភាពនេះជាបទពិសោធន៍ផ្លាស់ប្តូរជីវិតមិនត្រឹមតែសម្រាប់គ្រួសារប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់យើងទាំងអស់ដែលចូលរួមក្នុងការសាងសង់ផងដែរ។

ការចូលរួមសាងសង់ជាមួយអង្គការលំនៅឋានមនុស្សជាតិបានធ្វើឱ្យជីវិតរបស់ខ្ញុំកាន់តែមានភាពប្រសើរឡើង។ ខ្ញុំស្រឡាញ់ប្រជាជនកម្ពុជា ហើយនេះជាមូលហេតុដែលខ្ញុំបន្តគាំទ្រអង្គការលំនៅឋានមនុស្សជាតិ និងប្រទេសកម្ពុជាជានិច្ច។

មនុស្សគ្រប់រូបនៅលើភពផែនដីគួរមានកន្លែងមួយដែលពួកគេអាចហៅថា “ផ្ទះ” និងមានជម្រករស់នៅសមរម្យ។

អង្គការលំនៅឋានមនុស្សជាតិមានតួនាទីសំខាន់យ៉ាងខ្លាំងក្នុងការធ្វើឱ្យរឿងនេះក្លាយជាការពិត។ ខ្ញុំនឹងបន្តធ្វើការស្ម័គ្រចិត្តសាងសង់ឱ្យបានយូរតាមដែលខ្ញុំអាចធ្វើបាន។ វាជាបទពិសោធន៍ដ៏អស្ចារ្យបំផុតក្នុងឆាកជីវិតរបស់ខ្ញុំ។

> **“ ខ្ញុំចូលចិត្តចូលរួមសាងសង់ជាមួយអង្គការលំនៅឋានមនុស្សជាតិណាស់។ ការស្ម័គ្រចិត្តចូលរួមសាងសង់នៅតាមប្រទេសនានាជុំវិញពិភពលោក គឺបានបំពេញបំណង និងដួងចិត្តរបស់ខ្ញុំ។ លើកនេះជាលើកទី ៤ ហើយ ដែលខ្ញុំបានស្ម័គ្រចិត្តចូលរួមសាងសង់នៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំនឹងបន្តចូលរួមជានិច្ច។ ”**



Ms. Jenny, Global Village Volunter

# ៦ ទិដ្ឋភាពទូទៅផ្នែកហិរញ្ញវត្ថុ

## ចំណូល និងមូលនិធិបម្រុងទុក

**១,៦៥១,១៨២ ដុល្លារអាមេរិក**
វិភាគទាន និងការបរិច្ចាគ

**៣១,០១២ ដុល្លារអាមេរិក**
ចំណូលផ្សេងៗ

**១,៦៨២,១៩៤ ដុល្លារអាមេរិក**
ចំណូលសរុប

**៩២៣,៩៥១ ដុល្លារអាមេរិក**
មូលធិនិបម្រុងទុកដើមគ្រា



## ចំណាយ

**១,៥០៤,៤២៣ ដុល្លារអាមេរិក**
ចំណាយលើកម្មវិធី

**១៧២,៧៨០ ដុល្លារអាមេរិក**
ចំណាយក្នុងការរៃអង្គាសមូលនិធិ

**១៩២,៧០៨ ដុល្លារអាមេរិក**
ចំណាយផ្នែករដ្ឋបាល

**១,៨៦៩,៩១១ ដុល្លារអាមេរិក**
ចំណាយសរុប



# ៧ ដៃគូ និងអ្នកផ្តល់ជំនួយ

## ដៃគូ និងអ្នកផ្តល់ជំនួយអន្តរជាតិ

- អង្គការ Communities for Communities
- ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី
- អង្គការលំនៅឋានមនុស្សជាតិអូស្ត្រាលី
- អង្គការលំនៅឋានមនុស្សជាតិចក្រភពអង់គ្លេស
- អង្គការលំនៅឋានមនុស្សជាតិអន្តរជាតិ
- អង្គការលំនៅឋានមនុស្សជាតិអៀរឡង់
- អង្គការលំនៅឋានមនុស្សជាតិជប៉ុន
- អង្គការលំនៅឋានមនុស្សជាតិកូរ៉េ
- អង្គការលំនៅឋានមនុស្សជាតិហូឡង់
- អង្គការលំនៅឋានមនុស្សជាតិសិង្ហបុរី
- គណៈកម្មាធិការជំនួយ និងអភិវឌ្ឍន៍ក្រៅប្រទេស

## ដង្វាយមួយភាគដប់

- Christopher W. Platt
- អង្គការលំនៅឋានមនុស្សជាតិ Central Oklahoma
- អង្គការលំនៅឋានមនុស្សជាតិ Flagler
- អង្គការលំនៅឋានមនុស្សជាតិ Flatirons
- អង្គការលំនៅឋានមនុស្សជាតិ Grants Pass Area
- អង្គការលំនៅឋានមនុស្សជាតិ La Crosse Area
- អង្គការលំនៅឋានមនុស្សជាតិ Lakeland
- អង្គការលំនៅឋានមនុស្សជាតិ Midland
- អង្គការលំនៅឋានមនុស្សជាតិ Anderson
- អង្គការលំនៅឋានមនុស្សជាតិ Colorado
- អង្គការលំនៅឋានមនុស្សជាតិ Georgetown County
- អង្គការលំនៅឋានមនុស្សជាតិ Greater Cincinnati
- អង្គការលំនៅឋានមនុស្សជាតិ La Plata County
- អង្គការលំនៅឋានមនុស្សជាតិ Lee & Hendry Counties
- អង្គការលំនៅឋានមនុស្សជាតិ Northwest Connecticut
- អង្គការលំនៅឋានមនុស្សជាតិ Charlotte Region
- អង្គការលំនៅឋានមនុស្សជាតិ Greater La Crosse Region
- អង្គការលំនៅឋានមនុស្សជាតិ Wake Count
- អង្គការលំនៅឋានមនុស្សជាតិ Upper Cumberland
- Harlan Stone
- សមាគមអង្គការលំនៅឋានមនុស្សជាតិ Hawaii
- Robert S. Latimer

## ដៃគូសហការរដ្ឋាភិបាលថ្នាក់ជាតិ និងក្រោមជាតិ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានលំនៅឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ
- រដ្ឋបាលខេត្តសៀមរាប
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប
- មន្ទីររៀបចំផែនការខេត្តសៀមរាប
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តសៀមរាប
- រដ្ឋបាលខេត្តបាត់ដំបង
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តបាត់ដំបង
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង
- មន្ទីររៀបចំផែនការខេត្តបាត់ដំបង
- រដ្ឋបាលខណ្ឌព្រែកព្នៅ
- រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- រដ្ឋបាលខណ្ឌសែនសុខ
- រដ្ឋបាលខណ្ឌច្បារអំពៅ
- រដ្ឋបាលស្រុកបន្ទាយស្រី
- រដ្ឋបាលស្រុកប្រាសាទបាគង
- ការិយាល័យកសិកម្មស្រុកសង្គមថ្មី
- រដ្ឋបាលស្រុកសង្គមថ្មី
- រដ្ឋបាលក្រុងសៀមរាប
- រដ្ឋបាលខេត្តសៀមរាប
- រដ្ឋបាលស្រុកសូទ្រនិគម
- រដ្ឋបាលស្រុកវ៉ារិន
- រដ្ឋបាលក្រុងបាត់ដំបង
- រដ្ឋបាលស្រុកបវេល
- រដ្ឋបាលស្រុកសង្កែ
- រដ្ឋបាលស្រុកឯកភ្នំ
- រដ្ឋបាលស្រុកបាណន់
- រដ្ឋបាលស្រុកមោងឫស្សី
- សង្កាត់ត្រពាំងក្រសាំង
- សង្កាត់ចោមចៅទី ១
- រដ្ឋបាលសង្កាត់គោករកា
- សង្កាត់ឃ្មួញ
- សង្កាត់សំរោង
- រដ្ឋបាលសង្កាត់ព្រែកថ្មី
- រដ្ឋបាលឃុំដានរុន
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ
- រដ្ឋបាលឃុំព្រៃជ្រូក
- រដ្ឋបាលឃុំរអាង
- រដ្ឋបាលឃុំរុនតាឯក
- រដ្ឋបាលឃុំស្ដៅ
- រដ្ឋបាលឃុំស្រែណូយ
- រដ្ឋបាលឃុំត្រពាំងធំ
- រដ្ឋបាលសង្កាត់ស្វាយប៉ោ
- រដ្ឋបាលសង្កាត់វត្តគរ
- រដ្ឋបាលសង្កាត់ព្រែកព្រះស្ដេច
- រដ្ឋបាលសង្កាត់ទួលតាឯក
- រដ្ឋបាលសង្កាត់រតនៈ
- រដ្ឋបាលសង្កាត់ចំការសំរោង
- រដ្ឋបាលសង្កាត់ស្លាកែត
- រដ្ឋបាលសង្កាត់ក្ដុលដូនទាវ
- រដ្ឋបាលសង្កាត់អូរម៉ាល់
- រដ្ឋបាលសង្កាត់អូរចារ
- រដ្ឋបាលឃុំព្រែកនរិន្ទ
- មណ្ឌលសុខភាពព្រែកនរិន្ទ
- មណ្ឌលសុខភាពតាគ្រាម

## ដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ

- ក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍ (CEDT)
- អង្គការ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ)
- អង្គការគ្រិតគីសកម្ពុជា (GPC)
- អង្គការមនុស្សចាស់កម្ពុជា
- អង្គការអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ចជនបទ (HURREDO)
- អង្គការខ្មែរជំនាន់ថ្មី (KNGO)
- អង្គការពិភពកុមារ និងអភិវឌ្ឍន៍ (PE&D)
- អង្គការដើម្បីភាពញញឹមនៃកុមារ (PSE)
- អង្គការភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្មជនបទ (READA)
- ក្រុមហ៊ុន TapEffect CO., LTD
- អង្គការ TOUTES A LECOLE
- UN-Habitat

## សកលវិទ្យាល័យ និងសាលា

- សាលាអន្តរជាតិ CIA First
- សាលាបឋមសិក្សាឈូលាធំ
- សាលាអន្តរជាតិភ្នំពេញ
- សាលាអន្តរជាតិ ណតប្រ៊ីដ កម្ពុជា
- សាលាបឋមសិក្សាសម្តេចតេជោ ហ៊ុន សែន រុនតាឯក
- សាលាបឋមសិក្សាថ្មឈុល
- សាលាបឋមសិក្សាតាគ្រាម
- សាលាបឋមសិក្សាអូរពងមាន់

## ស្ថានទូត

- ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា

# សូមអរគុណដែលបានគាំទ្រដល់ពួកយើង

Habitat for Humanity

Habitat for Humanity Ireland

Habitat for Humanity Great Britain

Habitat for Humanity Australia

한국해비타트 Habitat for Humanity Korea

仁人家园 Habitat for Humanity Singapore

Habitat for Humanity Nederland

Habitat for Humanity Japan

Australian Aid

communities for communities — building communities together

Overseas Aid & Development Commission

# លោកអ្នកអាចចូលរួមជាមួយយើងខ្ញុំ

## បរិច្ចាគ

អំណោយជាហិរញ្ញវត្ថុរបស់លោកអ្នក មិនថាតិចក្តី ឬច្រើនក្តី នឹងជួយឱ្យអង្គការលំនៅឋានមនុស្សជាតិកម្ពុជា អាចជួយដល់គ្រួសារកាន់តែច្រើនជាងមុន និងសាងសង់លំនៅឋានដែលមានតម្លៃសមរម្យបន្ថែមទៀតនៅក្នុងប្រទេសកម្ពុជា។

## អ្នកស្ម័គ្រចិត្ត

លោកអ្នកក៏អាចចូលរួមជាមួយយើងក្នុងកម្មវិធីអ្នកស្ម័គ្រចិត្តរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា តាមរយៈការចុះកម្មសិក្សា ឬក្លាយជាអ្នកសាងសង់លំនៅឋានដោយចូលទៅកាន់គេហទំព័រ៖

www.habitat.org/cd/gv/schedule.aspx

## ទាក់ទងជាមួយនឹងបណ្តាញសង្គមរបស់យើង

តាមដានសកម្មភាពរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា តាមរយៈ៖

- HabitatCambodia1
- HabitatCambodia
- HabitatCambodia
- HabitatCambodia
- habitatcambodia.org





Habitat for Humanity
Rick
Siem Reap, 20 Oct - 24 Oct 2025
Habitat for Humanity
Colin
Siem Reap, 20 Oct - 24 Oct 2025
Habitat for Humanity
Spencer
Siem Reap, 20 Oct - 24 Oct 2025
Habitat for Humanity
Kerr
Siem Reap, 20 Oct - 24 Oct 2025
Habitat for Humanity
Bex


គម្រោងលំនៅឋានដែលមានភាពធន់ និងការតាំងទីលំនៅប្រកបដោយបរិយាបន្ន
Resilient Home, Inclusive Settlement Project
គម្រោងសាងសង់ផ្លូវក្នុងភូមិ
បណ្តោយ ១,០០០ម៉ែត្រ ទទឹង ៦ម៉ែត្រ
Community Road Construction
1,000m Long x 6m Wide
ចំណាយថវិកាសរុប៖ ៣,១៦៩ ដុល្លាអាមេរិក
ថវិកាពីគម្រោង៖ ២,៦០០ ដុល្លា និងថវិកាចូលរួម
របស់សហគមន៍៖ ៥៦៩ ដុល្លា
អនុវត្តដោយក្រុមប៉ាសា ភូមិបឹងធំ ឃុំគោកធ្លកក្រោម ស្រុកជីក្រែង
ខេត្តសៀមរាប
Total Budget: 3,169 USD
Project Budget: 2,600 USD and Community
Contribution: 569 USD
Implemented by the PASSA Group
in Boeng Thom Village, Kouk Thlok Kroam Commune,
Chikraeng District, Siem Reap Province
អនុវត្តដោយ | Implemented by
Habitat for Humanity
Cambodia
ផ្តល់មូលនិធិដោយ | Funded by
Habitat for Humanity
Great Britain
Overseas Aid &
Development Commission

លំនៅឋានមនុស្សជាតិកម្ពុជា
Habitat for Humanity® Cambodia

## ព័ត៌មានទំនាក់ទំនង

ការិយាល័យរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា


### ការិយាល័យរាជធានីភ្នំពេញ

លេខ ៤៨៧Eo ផ្លូវលេខ ៥៣BT ក្រុម ៦ ភូមិក្បាលទំនប់
សង្កាត់បឹងទំពន់ទី ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
+៨៥៥(០)២៣ ៩៩៧ ៨៤០

### ការិយាល័យខេត្តសៀមរាប

ភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប
ខេត្តសៀមរាប ប្រទេសកម្ពុជា
+៨៥៥(០)២៣ ៩៩៧ ៨៤០

### ការិយាល័យខេត្តបាត់ដំបង

លេខ ៣១៤ ក្រុម ២ ភូមិរតនៈ សង្កាត់រតនៈ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង ប្រទេសកម្ពុជា
+៨៥៥(០)២៣ ៩៩៧ ៨៤០


ប្រសិនបើអ្នកមានយោបល់ ឬគំនិតសម្រាប់ការកែលម្អដល់កិច្ចការរបស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជា សូមទាក់ទងមកកាន់យើងខ្ញុំ ៖


+៨៥៥(០)១២ ៤៨១ ០៩៨
feedback@habitatcambodia.org
heal.habitat.org